# ម៉ែខាត់

# រស់...ព្រោះហ៊ានស្លាប់

អបញ្ញាយរបស់ ឱ ឆតរង់

ចំនួន ៣០០០ ក្បាល

ព.ស. ២៥១៦ គ.ស. ១៩៧២

# អារម្ភកថា

●● អត្ថបទដែលមានចំណងជើងថា : ...សេ់គ្រោះហិនស្លាប់ នេះរៀបរៀងឡើងក៏ដោយសារមានបំណង ចង់ឲ្យបានការប្រុងស្មារតីរាល់រាង ខ្មែរ និង យួន ដែលកំពុងរឹតចំណងមិត្តភាពជាមួយគ្នាក្នុងគ្រាអាសន្ននេះទេ ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ចង់បង្ហាញនូវអ្វី ដែលអាចនាំឲ្យយើង បែកជាក់ថា អ្វីដែលយើងត្រូវរាង - ត្រូវជៀស - ត្រូវមានការអត់អោនគ្នាជាភាគី ។ អ្វីដែលយើងត្រូវធ្វើសហប្រតិបត្តិការដោយស្មោះ ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ។

ខ្មែរយើងតែងយកឃ្លាពាក្យភាសិតមួយប្រាប់ក-ូនចៅខ្លួនទៅថា : «ផ្ទៀងពួតជាពុំ អាកុំពោះការក្បឿង»: កុំតស៊ូប្រកាន់រកគប្បីរឹង ធ្វើកាប

មនុស្សម្នាក់ទៀត ទោះនៅក្នុងសភាពជាថ្មីទៀតក៏ដោយ ក៏អាចធ្វើឲ្យមនុស្សងាយនោះចប់ ហើយទំនើបប្រៈផាតឬជាតិ ។ មនុស្សយើងធ្លាប់ដកដង្ហើមតាមច្រមុះ បើគេខ្ទប់ច្រមុះ ទំដកតាមមាត់ទៀត បើគេបិទទាំងពីរ ក៏ទំព្រួសរកខ្យល់ចេញ–ចូលតាមមាត់ កាលណាគេខ្ទប់ច្រមុះទាំងពីរ ផងទាំងខ្ទប់មាត់ទៀត មនុស្សនោះតែងតែត្រូវ ដើម្បីជៀសវាងសេចក្តីស្លាប់ដោយការអស់ខ្យល់ដកជាស្វ័យប្រវត្តិ ។ យ៉ាងណាមិញ រឿងពិតដែលកើតឡើងនៅចុងឆ្នាំ ១៩៤៥ និងដើមឆ្នាំ ១៩៤៦ នៅកម្ពុជាក្រោម ក្នុងដែនដីសណ្ត ជាពិសេសក្នុងខេត្តឃ្លាំង និងភូមិកោះប្របាក ក្នុងខេត្តពលលាវ ដែលអស់លោកអ្នកកំពុងអាននេះ ក៏មានលំនាំផ្លូវការប្រៀបធៀបខាងលើនេះដែរ ។

ជាសំណាងល្អកាលនោះ ក្រោយពីការកាប់សម្លាប់គ្នាមក ខ្មែរ និង យួន បែរជានិយាយស្តាប់គ្នាបានទាន់វេលា បានជាកត្តានាំឲ្យខ្មែរនិងយួននៅទីនោះ ប្រែមករស់នៅជាមួយគ្នា ដោយសុខសាន្តវិញដូចដើម ។

ពេលចប់បញ្ញាក៏ផ្ដាំថា ជាតិសាសន៍ណា ដែលគ្មានអ្នកជាទីពឹងក្រៅពីពឹងលើខ្លួនឯង ឲ្យតែចេះនិយាយស្ដាប់គ្នាបាន - ចេះរួបរួមគ្នា - ចេះរក្សាអាថ៌កំបាំង-ចេះស្ដាប់មេ ស្ដាប់ [illegible] មានវិន័យ [illegible] ចេះស្ដាប់ ហើយហ៊ានស្លាប់ ជាតិសាសន៍នោះប្រាកដជាមិនស្លាប់ ។

បញ្ជាក់ : អត្ថបទនេះកើតឡើង [illegible] :

* ព្រះតេជគុណព្រះ [illegible]

* លោក [illegible]

* លោកតា [illegible]

ដោយសារថា ការណ៍នោះ ព្រះសង្ឃនិងអស់លោកទាំងនោះនៅជាសាក្សីនៅរស់នៅ [illegible] ក្រោយទាំងលោកតា [illegible] ដែលលោក [illegible] ។

●●●●

* ក្រុមជន ស៊ាង ដែលនាំក្រុមជនក្រុះក្លួយទៅ កន្លែងដែលគេកុង កាញ់ចំរុះបកស្អួចទឹក ក្បៀង ។

* ក្រុមជន ចាប់ រំ «ក្មួយលោកត្រូវទៅមកិ ការក្តី» ត្រូវរបួស ហើយត្រូវខ្មាំងប្អូសទៅ ភារ ក ហើងរត់ទៅស្រុមបិនទាន់ ។

* ក្រុមជន ២ នាក់ ដែលត្រូវខ្មាំងសម្លាប់ ពេលពេញកាត់ពិតក់ខ្មាំងយកទៅក្បែរនេះ ។

* ក្រុមជន ឡាំ គុន ដែលពេលកូនត្រូវគ្រាប់ កាលពេលបំបៅឱ្យកូន រហូតដល់ស្លាប់ទាំងខ្លួន ស្លាប់ទាំងកូន ។

* ក្រុមជន ឡាំ គីម ដែលត្រូវរបួស ហើយទំ កស្ទើរហូតខ្មាំងបាញ់ផ្តាច់ជីវិត ។

— ស៊ីង គាំង ដែលបានស្ទាញពោកគ្រាប់បែក «ក្ស៊ីប៊ីង់ក៍» ទៅទប់ខ្មាំង ក្រោយពីត្រូវរា ត្រូវបង្ខិលយកពោះបង់ពួក រហូតដល់ខ្មាំង បាញ់ស្លាប់ ។

ក្រោយទាំងនោះពេលពោះវិញ្ញាណក្ខន្ធបង-ប្អូន-ស្រី ប្រុស -ចាស់-ក្មេង ដែលបានបាត់បង់ជីវិត នៅក្នុងភាគប្រយុទ្ធ នោះ ក្នុងតែក-ផងស្ពាន-ផ្សារតេល-ព្រែកតាក-ម៉ឺនពេជ្រ- ស្លាកដឹក-ទួលគាង-ផ្សារតាសេក-ចាកទ្វីង-ចំងព្រៀក-ចិត

អក្សរ ។ល។ ក្នុងខេត្តខ្មែរ កើតឡើងជាតិ សាសន៍ កើតឡើង សេរីភាព កើតឡើងកុម្មុនិស្ត ។ និងកើតឡើងសំដែងសេចក្ដីលំបាក ជល់គ្នា-ខ្មែរនឹងខ្មែរឯង ទៅខ្មាំងប្រទេស និងខ្មាំងដទៃ ទៀត ទុក្ខណាណា ដែលត្រូវតែបញ្ហាគំនិតពួកខ្មែរ ផ្សេងៗគ្នា ហើយក្នុងខ្មាំង ដោយយកលេសថា យកទៅរៀន ឬ ទៅទទួលលោភកំ ។

ក្ដីស្នេហ៍របស់អស់លោក គឺជាក្ដីស្នេហ៍ដែលជាតិបាន មានប្រុងប្រយ័ត្ន ទៅតែងប្រគល់យក ជាក្ដីស្នេហ៍ដែលគេត្រូវតែ ទៅរក ។

សូមនេះ អស់លោក អ្នក ដែលបានចាប់ផ្ដើមនេះទៅ ទៀតហើយ ប្រកបដោយការស្រឡាញ់ទៀងនេះ សូមអស់លោក ស្គាល់ដោយបេះដូងស្មោះទៅ អស់កម្ម អស់កណ្ដ ។

❀

# ឧទ្ទិស

ពេលដែលខ្ញុំចាប់ផ្ដើមរៀបរៀងអត្ថបទ «...រស់ព្រោះហ៊ានស្លាប់នេះ» ខ្ញុំសូមលើកដៃទាំងទ្វេដាក់លើសិរសា ឧទ្ទិសដល់វិញ្ញាណក្ខន្ធ ៖

* អ្នកម្ដាយដែល ដែលមិនព្រមបញ្ចេញក្ដីស្នូក ដែលគាត់មានចំពោះខ្ញុំ ពេលដែលគាត់បានដឹងថា ខ្ញុំទទួលភារៈដឹកនាំការតស៊ូនៅកម្ពុជាក្រោម ។
* លោកតា ថាច់ ហ៊ុយ អាយុ ៨០ ឆ្នាំ ដែលបានលះបង់ប្រាណ:គាត់ជាអាចារ្យ យករូបប្រយុទ្ធជាមួយយើង ។
* លោក ឡាំ ណុយ អាយុ ៩០ ឆ្នាំ ដែលបានលើកទង់ជាតិខ្មែរជាដំបូងបំផុតនៅមុខទីកស្ដោះទៅកន្ទាំង ។

# [illegible]



[illegible]

កាលពី ឆ្នាំ ១៩៣៨

*** ខ្ញុំ ម៉ៃ ខាត់ ខាងដើម ម៉ៃ ជាត់ ។ សរសេរដោយអក្សរឡាតាំង Mai Khach ត្រូវអានជា ម៉ៃ ខាច់ ដូច្នេះ គ្រួសារខ្ញុំ ស្គាល់ខ្ញុំជា ជាត់ យួនហៅខ្ញុំតាមអក្សរគេជា ខាត់ ចិនហៅខ្ញុំ ម៉ួយ ខិ បារាំងហៅខ្ញុំ កាត្ស · «កីឡាប៉េតាប់ ម៉ីង្យាង» ។ អ្នកផ្តួចការអានឈ្មោះខ្ញុំ ខាច់ ។ នៅឯស្រុកកំណើតកម្ពុជាក្រោម គេស្គាល់ខ្ញុំជា *ថី សោយ ផាត់* ។ លុះចូលមកបម្រើក្រសួងអភិវឌ្ឍន៍សហគមន៍ ខ្ញុំបានទទួលឈ្មោះមួយទៀតប្រកបដោយប្រិយភាព គឺលោកតា ខាត់ ។

រីឯខ្លួនឯងវិញ ខ្ញុំទំប្រាប់គេ-ឯងថាខ្ញុំឈ្មោះ ខាត់ គឺព្រោះមិនចង់ឲ្យគេហៅឈ្មោះខ្ញុំតាមសំបុត្រកំណើត ដែលសរសេរឈ្មោះខ្ញុំខុស ជាត់ ជា ខាត់ មិន ខាត់ ជា ខាច់ នោះទេ ។

កុមារ ខាត់ កើតនៅថ្ងៃ ២៣-១១-១៩១១ ខុសត្រូវគ្នាពីរឆ្នាំពីសំបុត្រកំណើត ដែលចុះខុសទៅជាថ្ងៃ ២៣-១១-១៩១៣ ។ ដូច្នេះ បើគិតមកដល់ថ្ងៃសរសេរអត្ថបទ នេះ

ខ្ញុំត្រូវមានអាយុ ៦០ ឆ្នាំ ២ ខែ ២៨ ថ្ងៃហើយ មិនមែន ៥៨ ឆ្នាំទេ ។ ខ្ញុំកើតនៅភូមិផ្អោកំបុត សង្កាត់ព្រែកតយ ស្រុកអណ្តូងទឹក ខេត្តឃ្វាំង ។

គ្រួសារខ្ញុំ ជាកសិករមានអំបូរជាខ្មែរអ្នកជា ជាអ្នកមានធនធានមធ្យម ។ គ្រួសារខ្ញុំជាគ្រួសារស្លូតបូត ប្រកបដោយសប្បុរសធម៌ទូលំទូលាយណាស់ ។ បានកសាងព្រះវិហារ កុដិ សាលា ក្នុងវត្តពោធិព្រឹក្ស និងស្ពានក្បែរវត្តនោះនៅគង់វង្សរហូតសព្វថ្ងៃ ។ បានបំណាយដីស្រែផ្ទាល់ខ្លួនមួយចំនួនធំ សម្រាប់ធ្វើជាទ្រព្យគុរុភណ្ឌ និងជូនដីភូមិបណ្ដោយមួយពាន់ម៉ែត្របាយ សម្រាប់អ្នកទីទ័លក្រសង់ផ្ទះនៅរហូតសព្វថ្ងៃដោយឥតយកឈ្នួល ។

ជីដូន-ជីតា-ឪពុក-ម្ដាយខ្ញុំ គាត់មិនស្អប់ទេអ្នកមាន តែច្រើនរាប់រកអ្នកក្រជាង ហើយស្រឡាញ់អ្នកវេះដឹង ។ ប្រហែលជាដោយសារហេតុចុងក្រោយនេះហើយ បានជាលោកបំណាយធនធានឱ្យខ្ញុំមក «ស៊ីរៀន» នៅភ្នំពេញចាប់តាំងពីថ្ងៃ១៣ មេសា ១៩២០ «ខ្ញុំអាយុ៩ឆ្នាំ» ។

អក់ព្វណាស់ ខ្ញុំរៀនស្រះអ ស្រះអា នៅស្រុកកំណើត រៀនអា បេ នៅភ្នំពេញ ទៅប្រឡងចូលកូលេសនៅស្រុកយួន ។ មកដល់ត្រឹមនេះ ខ្ញុំមានជំនឿថា អស់លោកអ្នកអានអាចសន្និដ្ឋានបានថា ខ្ញុំមានការវេះដឹងដល់ណា ។

ខ្ញុំខូចចិត្តណាស់ ដោយបំពេញបំណងជូនមាតា-បិតា មិនបានដូចចំណង់របស់លោក ប៉ុន្តែលោកមានធម៌មេត្តាចំពោះខ្ញុំជានិច្ច ព្រោះលោកជាមនុស្សជឿធម៌ ជឿអាថ៌ ដោយលោកបានបញ្ជាក់មកខ្ញុំវិញថា « ឯង គ្មានធម៌បុព្វេដូចគេ » ។

ក្នុងឆ្នាំ ១៩៣៦ ក្នុងកាលខ្ញុំជាមនុស្សម្នាក់មានព្រលឹងតែទៅលើការកសាងកុសល ក៏ក្លាយទៅជាយុទ្ធជនស្ម័គ្រចិត្តម្នាក់ ទទួលបៀវត្សប្រចាំខែ ៣រៀល ៦កាក់កន្លះ ។ នេះជាផលវិបាក គ្រួសារមួយដែល[illegible]មនុស្សចិត្តធម៌ ទៅជាមនុស្សរៀនកាប់ចាក់បាន ។

ចាប់តាំងពីឆ្នាំ១៩៣៦ មក ខ្ញុំដែលធ្លាប់តែធ្វើអំពើល្អ ធ្លាប់តែឮពាក្យខ្ញុំខ្មានឲ្យជេរ ផ្ទាល់ ផ្ទៃក្រៅ ក៏យ៉ាងដូចជាលោកតាខ្វាក់ ដែល ខ្ញុំ ដែលអ្នកផងទទួលស្គាល់ថាគាត់មានលក្ខណៈជាអ្នកដឹកនាំ ហើយមានងារជាឧត្តមប្រឹក្សារបស់រដ្ឋការខេត្តឃុំទង គាត់តែងខ្មានខ្ញុំថា: កើតមកជាមនុស្ស បើមិនបានធ្វើល្អ ក៏តែប្រព្រឹត្តអាក្រក់-បើមិនបានធ្វើបុណ្យ ក៏តែសាងបាប ធ្វើឲ្យគេទឹកភ្នែក ជៀសវាងមិនរួចតែពេលមានសង្គ្រាមឯណោះនោះ ក៏ខ្លួនខ្ញុំក្លាយទៅជាអ្នករៀនតែបាញ់ ប្រយុទ្ធ ដោយកាប់ក-ចាក់ពោះទុង-រៀនតែបច្ចេកទេសខាងសម្លាប់សត្រូវ ។

ក្រោយពីបានចូលរៀនក្នុង សាលា យោធានានា នៅ ក្រុងព្រៃនគរ នៅទួលតាមោគនៅអ្នកតាប់មក ខ្ញុំបានទទួល សញ្ញាប័ត្រ ប្រើវើដីសេហ្វឺលិចស៊ីយ៉ុង ក្នុងឆ្នាំ ១៩៣៧ដែល មានពិន្ទុរហូតដល់ទៅ ១៨,៣៦ ក្រោយមកបានបំពេញវិជ្ជា ផ្នែកវិជ្ជាយុទ្ធសាស្ត្រអនុវត្តប្រឡងចេញជាប់លេខ ១ ឆ្នាំ ១៩៦១ ខ្ញុំធ្វើជាគ្រូបង្ហាត់វិជ្ជាយុទ្ធសាស្ត្រនៅទួលតាមោគ «កម្ពុជាក្រោម» ។ ក្រោយមក ខ្ញុំបានប្រឡងចិនសៀម និងជប៉ុន និងយៀកមិញ ។ ឧត្តមសេនីយកំហាវឈ្មោះ ត្រឹង យុវឹង ស្វាយ ហៅ ណាវ៉េ បានឱ្យគេតាមសម្លាប់ ខ្ញុំ ។ ខ្ញុំក្រឡាប់ឡាន ៣ ដង បាក់ស្មារទាំងពីរ ។ ខ្ញុំត្រូវ របួសពេលប្រយុទ្ធនៅហាវទៀង ។

នៅយប់ ៩ មីនា ១៩៦៥ ខ្ញុំត្រូវជប៉ុនចាក់ទីងចំពុះទុង តាមប្រហោងទ្វារដែក ប៉ុន្តែជាសំណាងល្អ ខ្ញុំគេចផុត ។

ព្រលឹមថ្ងៃ ១០ មីនា ១៩៦៥ ខ្ញុំប្ដូរស្នាប់ដើម្បីយក ចៅហ្វាយចាស់ដែលបរាជ័យ ទៅលាក់នៅភូមិចាម ហៅ ភូមិ ចួរយ៉ាង. ក្នុងស្រុកមាត់ជ្រូក ។ រសៀលថ្ងៃ ១០ មីនា ១៩៦៥ ខ្ញុំត្រូវជាប់គុកជប៉ុន ។ ពេលយប់ខ្ញុំគេច រត់រួចទៅលាក់ខ្លួនក្នុងព្រុំងពៃនៅផ្ទះយួន ដែលខ្ញុំស្គាល់ នៅជិតផ្សារទាងស៊ើ ។ ព្រឹកឡើងយកអីវ៉ាន់បន្តិចបន្តួច ចាក្រសារ និង ភូតភួចៗ ធ្វើដូចទៅនៅផ្ទះចាម នៅភូមិ

ស្វាយ ត្រូវចាមលួចអស់ខ្ទះ ។

ថ្ងៃ ២០ មីនា ១៩៤៥ យួនដែលខ្ញុំជួលនោះខ្ចាត់ខ្ចាយទៅ ស្រុកកំណើត ត្រាច់ដាច់សម្ងាប់ខ្ញុំដើម្បីយកអីវ៉ាន់ផ្លូន ទៀត ប៉ុន្តែសំណាង បានមិត្តភក្តិដែលនៅជាមួយជិតខាង ។

បារាំងចាញ់ជប៉ុន ខ្ញុំត្រូវអស់លក្ខណ៍ទៅសម្រាកធ្វើស្លូត ក្នុងផ្ទះឪពុក-ម្តាយនៅកម្ពុជាក្រោម ។ ខ្ញុំរៀនត្បាញ ចេះ ដេរ ចេះចារ ឲ្យបាយអំបោះ ចេះអន្លូង ។ល។

យួនតែងនៅផ្ទះខ្ញុំរកការកើន យួនយកខ្ញុំធ្វើជាសត្រូវ ។ ម៉្លោះហើយ ខ្ញុំចិញ្ចឹមកិរិយាខ្ញុំ ដោយញាតិមិត្តជួយផង ខ្ញុំរស់ នៅជាមួយញាតិមិត្ត ហើយទទួលយកស្រែពីម្តាយ-ឪពុកខ្ញុំ ធ្វើបានជាង ១.០០០ជាវ ស្រូវក្នុងឆ្នាំនោះ ។

ថ្ងៃ ២ មករា ១៩៤៦ ខ្ញុំត្រូវបង្ខំចិត្តដឹកនាំចលនា តស៊ូនៅកម្ពុជាក្រោម ដែលអ្នកម្ចាស់មានអំណាច មាន មហិទ្ធិឫទ្ធិ អ្នកម្ចាស់ទៀត គ្មានអ្វីមានក្រៅពីខ្លួនបង់រស់ជា មនុស្សមានសេរីភាពក្រោមគន្ធិយុត្តិធម៌ ។ ជានាកប្រ យុទ្ធមួយដ៏ទី ប៉ុន្តែសាហាវ ក្រៃណាសាហាវ ដូចខ្ញុំនឹង រៀបរាប់ជូនក្នុងទំព័រខាងក្រោមនេះ ។

ពីរខែក្រោយមក ពេលបារាំងត្រឡប់មកវិញ ស្រួល បួលហើយ គេឲ្យខ្ញុំធ្វើអភិបាលស្រុក ។ ក្នុងមុខងារថ្មី នេះ ខ្ញុំបានធ្វើការកសាងសន្តិភាព រហូតដល់គួសត្រូវ

និយាយស្តាប់គ្នាបានដូចដើមវិញ ហើយបានក្សោសន្តិភាព រាប់រកគ្នារហូតសព្វថ្ងៃ ។

ចុងឆ្នាំ ១៩៤៦ ខ្ញុំបានទទួលប្រាជ្ញាសក្តិជា ព្រឹទ្ធបាលទោ ហើយទទួលបញ្ជាឲ្យចូលបម្រើកងទ័ពសម្ព័ន្ធមិត្តនៅក្នុងកងពលលេខ ៤៣ ដែលមានសកម្មភាពនៅក្នុងខេត្តទឹកខ្មៅ ក្នុងមុខងារជាមេបញ្ជាការកងអនុសេនាតូច ដែលមាននាយទាហានវៀត និងពលទាហានជាជាតិបារាំងសុទ្ធ ។

ឆ្នាំ ១៩៤៧ ខ្ញុំត្រូវផ្លាស់មកមាត់ជ្រូក ក្រោយមក មកនៅតាកែវ និងកំពត មានប្រាជ្ញាសក្តិជាព្រឹទ្ធបាលឯក បំពេញមុខងារជានាយទាហានទាងបរិក្ខារក្នុង កងវរសេនាតូចនៃកងទ័ពជាតិ ដែលមានវរសេនីយ៍ទោ តូម៉ា ជាមេបញ្ជាការ ។

ឆ្នាំ ១៩៤៩ ខ្ញុំចូលមកធ្វើជានាយករងនៃការិយាល័យគតិយាន នៅវរសេនាធិការដ្ឋាននៃកងទ័ពសម្ព័ន្ធមិត្តនៅក្រុងភ្នំពេញ ។

ចាប់តាំងពីថ្ងៃ ២៥-១១-១៩៥០ ខ្ញុំធ្វើជាអភិបាលស្រុកមេមាស-កំពង់លែង ខេត្តកំពង់ឆ្នាំង ស្វាយទៀប-ស្វាយរៀង ខេត្តស្វាយរៀង បន្ទាយមាស-កំពត ខេត្តកំពត និង ទៅសួង ខេត្តកំពង់ចាម រហូតដល់ឆ្នាំ ១៩៦៤ ដែលជាថ្ងៃចូលនិវត្តន៍ ។ ក្នុងមុខងារថ្មីដែលខ្ញុំបំរើអស់ ១៤ ឆ្នាំ ខ្ញុំ

បាទក៏ក្លាយទៅជាមន្ត្រីរដ្ឋបាលមួយរូប ដែលខិតខំធ្វើការ ហើយប្រមែប្រមូលបងប្អូនយើង ដែលវង្វេងវង្វាលមករកសង្គមជាតិវិញចំនួន ជាង៥០០ នាក់ ។ ខ្ញុំបានយកចិត្តទុកដាក់ជាពិសេសទៅលើការប្រយុទ្ធជាមួយពួកឈ្លានពាន និងរួមដំណើរជាមួយសង្គមខ្មែរឆ្ពោះទៅរកវឌ្ឍនភាព តាមកម្លាំងដែលខ្ញុំធ្វើទៅបាន មានជួយរំដោះបងប្អូនខ្មែរលើឲ្យរួចផុតពីកណ្ដាប់ដៃខ្មាំង នៅឃុំក្បាលទឹក - តាវែងផ្ទាល - តាប្រង់ច្រើនពាន់គ្រួសារក្នុងខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៥៤ ជាដើម ។ ក្នុងឆ្នាំ ១៩៥៩ ធ្វើជាជំនួយខេត្តទី ១ នៃខេត្តស្វាយរៀង ។ ក្នុងការប្រឹងប្រែងនេះ ខ្ញុំបានទទួលឥស្សរិយយសការពារជាតិចំនួន ៣ រាប់ទាំងរបស់សាធារណរដ្ឋបារាំងមួយ គ្រឿងផង មេដាយមាស ៧ មេដាយប្រាក់និងសំរឹទ្ធ ១០ គ្រឿងទៀត ។ល។

ក្រោយ ១៨ មីនា ១៩៧០ គឺនៅថ្ងៃ១ ខែសីហា១៩៧០ ខ្ញុំបានទទួលឋានន្តរសក្ដិជា អនុសេនីយឯក ហើយបានមកបំរើក្រសួងអភិវឌ្ឍន៍សហគមន៍រហូតសព្វថ្ងៃ ក្រោយពីបានចូលបំពេញវិជ្ជានៅបណ្ឌិតសភាយោធានៅក្រុងភ្នំពេញ ។

# ឆាកប្រយុទ្ធ ខ្មែរ-យួន នៅ កម្ពុជាក្រោមក្នុងឆ្នាំ១៩៤៥-៤៦

រឿង... រស់ព្រោះហ៊ានស្លាប់នេះ ជាចំណងជើងនៃឆាកប្រយុទ្ធដ៏ខ្លី ប៉ុន្តែឃោរឃៅបំផុត ចាប់ពីថ្ងៃទី ២ មករា ១៩៤៦ អស់កំឡុងពីរខែ រវាងអ្នកមានអំណាច និងក្រុមមនុស្សដែលមិនព្រមចុះចាញ់ ដោយមិនទាន់បានបង្ហាញនូវវីរភាពដែលគេមាន ។

ឆាកប្រយុទ្ធដើម្បីសេរីភាពនិងយុត្តិធម៌នេះ បានកើតឡើងជាដំបូងនៅក្នុងសង្កាត់ ព្រែកគយ ស្រុកអណ្តូងទឹក ខេត្តឃ្លាំង ក្នុងដែនដីសណ្តនៃទន្លេមេគង្គ នៅកម្ពុជាក្រោម រួចក៏រាលដាលទៅច្រើនខេត្តទៀត ។

រឿង...រស់ព្រោះហ៊ានស្លាប់ និងបង្ហាញម្តងទៀតនូវកម្លាំងរបស់សង្គមមួយ ដែលចេះរួមគ្នា ចេះស្លាប់គ្នា ជាពិសេសក្នុងការឈមមុខទល់នឹងសត្រូវ ។

# ផ្នែកភាគ៣

# ភូមិសាស្ត្រនិងមនុស្ស

ខេត្តឃ្លាំង ជាខេត្តមួយជាប់ខេត្ត ក្រមួនស-ព្រះត្រពាំង-ព្រែកឫស្សី-ពាមបារ៉ាជ-មាត់ជ្រូក-ពលលាវ ។ អំពូយាទឹកខ្មៅ ។ល។ ដែរ គឺស្ថិតក្នុងដែនដីសណ្ដរនៃទន្លេមេគង្គ ។ តាមតាទួតខ្ញុំប្រាប់ថា ខេត្តនេះកាលដើមឡើយនៅក្រោមអាណាព្យាបាលរបស់ខ្មែរនៃខេត្តបន្ទាយមាស «កំពត» ។ ខេត្តឃ្លាំងជាខេត្តមានគមនាគមន៍បរិបូណ៌ តាមទឹកក៏ដូចជាផ្លូវគោក ។ នៅប៉ែកខាងកើតមានមាត់ទន្លេមេគង្គ ដែលហូរចេញជាពីរពាម ចេញទៅសមុទ្រ នាំល្បប់ទៅដាក់កើតជាដីថ្មីដុះឡើង ៗ រៀងរាល់ឆ្នាំ ។ ដីល្បប់ហូរដល់ណា ដើមឈើដុះដល់នោះ ប្រជាពលរដ្ឋទៅតាំងលំនៅដ្ឋាននៅទីនោះបន្ទាប់បន្តទៅ ។

ពលរដ្ឋនៃខេត្តឃ្លាំង ដែលជាម្ចាស់ដើម មាននៅគុះគរាប់ពាន់នាក់ ក្នុងភូមិនិមួយ ៗ ដែលមានខ្លះ មាន

បណ្ដោយរហូតដល់ទៅ ៧ គ.ម.ឆ្ងាយ ដូចជាភូមិផ្កាកំបុត- ភូមិព្រៃកគយ - ភូមិដងក្ដោង - ភូនក្អែក - ដើមពោធិ - ភូមិខ្ទិនតាង - កំពង់ឈើទាល - ភូមិដៃនុង - ព្រៃកខាក - បឹងព្រលិតតានាវ - មាន់គោង - ផ្ដៅពេន - ទន្ទេងឯត្បូង - ភូមិឯលិច - ភូមិផ្ការីក ។ល។ (១) ។ លំនៅឋានច្រើនសង់របៀបបោរាណដោយកាលជំនាន់មុន សព្វថ្ងៃចាប់ផ្ដើមមានផ្ទះថ្មព្រោងព្រាត ។ អ្នកស្រុកដែលនៅជិតមាត់ទឹក គេច្រើនជីកប្រឡាយទឹកខ្វាត់ខ្វែងនៅជុំវិញផ្ទះដើម្បីឱ្យទឹកចូល បានត្រីទទួលទានផង ដាំដើមដូង ដើមចេក លើសាច់ដីលើកនោះផង ។

របររកទទួលទានតែធ្វើស្រែ មិន ខេសាច ។ ដីស្រែនៅត្រង់ទិសទិលាតសន្ទឹងដាច់កន្ទុយក្អែក ។ កាលពីជំនាន់ដើម ពលរដ្ឋខ្មែរជាច្រើន សុទ្ធសឹងតែជាម្ចាស់ដីកម្មសិទ្ធិរាប់រយហិកតារៗក្រោយពីរដ្ឋការយៀកណាមធ្វើនយោបាយកែប្រែចំរង់ដីមក ម្នាក់ៗ មានត្រឹមតែដីដែលខ្លួនប្រកបរបរដោយផ្ទាល់ គឺមានពីមួយ ដល់ ១៩ ហិកតារប៉ុណ្ណោះ។ បងប្អូនយើងនៅស្រុកនោះ ពុំសូវប្រើគោទេ ប៉ុន្តែមានក្របីរាប់ពាន់ រាប់ម៉ឺនក្បាល ។ នៅរដូវស្រែ មានកសិករខ្លះមាន

---

*(១) គួរឲ្យប្រមោថក្នុងចិត្តណាស់ កាលបើឃើញភូមិមានឈ្មោះជាខ្មែរ ហើយបែរជាពុំមែនរបស់ខ្មែរទៅវិញ ។*

ម៉ាស៊ីនភ្ជួរ សំរាប់ស៊ីឈ្នួលភ្ជួរដី កសិករភាគច្រើនមានមធ្យោបាយដឹកនាំផ្ទាល់ជាកាណូតតូច ៗ ឬទូកតិរ ៗ នៅក្នុងភូមិនិមួយ ៗ គេឃើញមានដើមឫស្សី ពិងពង់ ដើមឈើផ្លែ ដូចជា ដូង ស្វា ស្វាយ ស្វាយចន្ទី ក្រឹង ៗ ដើមក្រូច ឬ ធូរេន ត្នោត ពុំសូវមានទេ ៗ ប៉ុន្តែស្រុកនោះសំបូរណ៍ដើមចាក ដែលអ្នកស្រុកនាំតាមមាត់ព្រែកសំរាប់យកស្លឹកប្រក់ផ្ទះ ៗ ត្រីស្រែ ត្រីសមុទ្រ បង្គា ក្តាមសមុទ្រ សំបូរណ៍ហូរហៀរ នៅផ្សារបុណ្យភ្ជុំបិណ្ឌ ៗ នៅផ្សារព្រាំង ខ្យក់ត្រីស្រែ តែមានត្រីសមុទ្រទទួលទានគ្រប់គ្រាន់ ៗ ហេតុដូចនេះហើយ បានជាគេពុំដែលទទួលទានក្តាមស្រែទេ ៗ ជនណាទទួលទានក្តាមស្រែ គេចុកជាមនុស្សអន់ ដូចជាអ្នកកម្ពុជាកណ្តាលទីមគេញ៉ូផ្លោះផែរ ៗ បើស្រែណាមានក្តាមច្រើនកាត់សន្ទូង គេដាក់ទ្រូយកទៅបុកចោល ៗ សង្គមខ្មែរកម្ពុជាក្រោមភាគច្រើន ជាអ្នកមានចរិយាស្លូតបូត តែទាំងអស់គ្នាសុទ្ធតែមានចិត្តមោះមុតក្លាហាន ជាពុទ្ធមាមិកជនគេរាប់រកគ្នាណាស់ គេឥតចេះផ្ចញ្ចក្តីក្តាំទេ ៗ ការទាស់ទែងទែងគំនិតគ្នា គេច្រើនហៅរកមនុស្សចាស់ឲ្យជួយផ្សះផ្សាសំរុះសំរួល ៗ គេមានគំនិតសហគមន៍ខ្ពង់ខ្ពស់បំផុត ៗ រដូវស្រែ គេយកដៃគ្នា ហើយគេចាប់ផ្តួបផ្តុំគ្នាពីម៉ោង ៤ ភ្លឺជាក្រុមតាមតិច តាមច្រើនទៅជួយកិច្ចការគ្នា រហូតបានសំ

ររ០ ៗ លុះវិលមកដល់ទីលំនៅវិញរវាងម៉ោង ១០ ព្រឹក គេចាប់ធ្វើកិច្ចការនៅផ្ទះ ដូចជា ត្បាញល្អី កញ្ជើ ឬវេញខ្សែ ពោលគឺ គេច្រើនទៀតធ្វើឱ្យពេលវេលាមានតម្លៃរហូតពេលនិទ្រា ៗ រដូវក្ដៅ រាស់ ស្ងួន ក៏ដូចជារដូវច្រូតកាត់ ពោកបែនផែរ ៗ ម្ចាស់ស្រែនិមួយ ៗ បំរើភ្ញៀវដែលទៅជួយកិច្ចការខ្លួនដោយស្រា បារី រំពងម្ហូប និងនំបន្ថែម គេច្រើនចំហុយត្រីប្រៃ ពងទា ឬ ទត្រី ឬ សាច់ជ្រូក ជាពិសេស គេច្រើនស្ងោរស្លនិងស្លរស ដែលនៅស្រុកនោះគេនិយមឱ្យឈ្មោះថា ទណ្ដៅ ស្រួបលើបាយដំណើប ដូចរបៀបធ្វើចេកខ្ទិះបាយដំណើប នៅកម្ពុជាកណ្ដាលដែរ ៗ

ពេលច្រូតកាត់ ជាពេលសប្បាយ ពីព្រោះមានអ្នកលក់នំ ចំណីគ្រប់បែបយ៉ាងតែងតែទៅលក់សព្វទិសទី ៗ ក្រោយពីពេលដឹកគ្រាប់ស្រូវដល់ជង្រុកហើយ គេប្រើត្បាល់ជាន់ឬត្បាល់កៀនបុកអង្ករ ៤ ធ្វើជាអង្ករទុកទទួលទានសម្រាប់មួយឆ្នាំ ៗ បន្ទាប់មក គេនេសាទត្រីក្នុងអណ្ដូង ដែលគេដឹកឱ្យត្រីចូលក្នុងផ្លូវស្បា ឬនេសាទរបៀបផ្សេង ៗ ទៀត ដើម្បីធ្វើ ប្រហុក ផ្អក មាំ ទុកទទួលទានគ្រប់គ្រាន់សំរាប់ឆ្នាំនិមួយៗ ៗ

ពេលសប្បាយគឺពេលចូលឆ្នាំ តែគេឥតលេងល្បែងប្រជាប្រិយទេ បើមានត្រឹមតែចាក់ចាប់ក្នុងវត្ត ដែលជួន

កាលមានយួនចូលរួមផង ចំពោះវត្តណាដែលនៅជិតផ្សារ ៗ នៅពេលភ្ជុំបិណ្ឌ ទំលាប់ស្រុកនោះគេសែនបីថ្ងៃ ៗ នៅពេលសែនម្ដង ៗ គេតែងធ្វើម្ហូបអាហារប្រណីត ជាពិសេសគេធ្វើទាទឹម រួចគេអញ្ជើញញាតិមិត្តជិតខាងមកជួយអបអរសាទរ ៗ ផងជាតិយួន ចិនខ្លះក៏ត្រូវបានអញ្ជើញចូលរួមផង ដែលនៅកន្លែងដែលមានយួនចិននៅក្បែរ ៗ

បុណ្យកឋិន បុណ្យផ្កា បុណ្យកំសាន្ត ក៏ត្រូវបងប្អូនយើងគោរពធ្វើតែរៀងរាល់ឆ្នាំដែរ ហើយនៅក្នុងពិធីបុណ្យទាំងនោះ គេឃើញផងជាតិយួនចូលរួមជាពុទ្ធមាមិកផង ឬជាអ្នកលក់ដូរ ៗ សូមជំរាបថាយួន ឬ ចិន ដែលមានអ្នកខ្លះចូលទៅតាំងលំនៅដ្ឋានជាមួយភូមិខ្មែរ ច្រើនតែកាន់ទំនៀមទំលាប់តាមមនុស្សភាគច្រើន រហូតដល់ស្លៀកពាក់និងជំនឿផងទៀតដូចខ្មែរ ថែមទាំងនិយាយភាសាខ្មែរទៀតផង ៗ

បងប្អូនយើងនៅកម្ពុជាក្រោមស្រឡាញ់កីឡា ដោយហេតុនេះហើយបានជានៅរដូវប្រាំង គេតែងឃើញយុវជនប្រព្រឹត្តល្បែងបាល់ទាត់នៅតាមវាលស្រែខ្លះ ឬ តាមភូមិដែលឥតមនុស្សនៅ ៗ ការប្រកួតគឺធ្វើឡើងរវាងភូមិមួយនិងភូមិមួយទៀត ឬរវាងខ្មែរនិងយួន ឬចិន ៗ

ខេត្តឃ្លាំង-ខេត្តពលលាវ «ខេត្តពីរជាប់គ្នា» ជាខេត្តមានទូកង ច្រើនបំផុត ហើយអ្នកស្រុកនៅនិយមកីឡានេះរហូតសព្វថ្ងៃនៅពេលភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ បុណ្យកឋិនទាន ឬ ចូលរួមក្នុងពិធីអ្វីមួយ ។

ល្ខោនបាសាក់ជាល្ខោនមានប្រជាប្រិយភាពបំផុត នៅកម្ពុជាក្រោម ពីដើមកាលស្រុកគ្មានចំបាំង គេឃើញមានក្រុមល្ខោនសើចគ្រប់សង្កាត់ ក្រៅពីនេះមានរបាំយីកេ និងរៀបចំចាប៉ី មានវង់ភ្លេងពិណពាទ្យ ភ្លេងខ្សែសំរាប់កំសាន្ត ។

ក្នុងពិធីអាពាហ៍ពិពាហ៍ បងប្អូនយើងនៅប្រកាន់របៀបបូរាណដោយភាគច្រើន ដូចជាកូនប្រុសពាក់អាវក្រហម ស្លៀកហូលចងក្បិន ស្រីពាក់អាវបំពង់ពណ៌ សក់បួងរបៀបបូរាណ ចងក កន្សែងចាបុច ។ ខ្នើយផ្ទឹមគេច្រើនប្រើខ្នើយមុខបី ដែលពាក្យក្រៅហៅខ្នើយពូថៅ ។ អាពាហ៍ពិពាហ៍ដែលកំណត់ពេលបីថ្ងៃ មានជួនកាលមានធ្វើពិធីបុកលក្ខណ៍ និងពិធីធ្វើឆ្នេញ ។ ម្ហូបអាហារទទួលភ្ញៀវពី ១០ ឆ្នាំមុន គេនៅឃើញមានរបៀបរៀបចំចានម្ហូបមានជាន់បីដាក់លើថាសស្ពាន់ មានជើងបួនរូបគុន ។ សម័យនេះគេរៀបចំទទួលភ្ញៀវតាមរបៀបសម័យដូចគេដូចឯងអស់ទៅហើយ ។

ចរិតចិត្តបងប្អូនយើងនៅកម្ពុជាក្រោម គឺជាចរិតចិត្តជា

អ្នកជាតិនិយម ហើយប្រកបដោយវិភាគផង ៗ ជីតាខ្ញុំតែងនិទានពីធាតុប្រយុទ្ធរវាង ខ្មែរ-យួន កាលក្នុងសតវត្សទី ១៩ ជាច្រើនលើកនៅវាលស្រែមួយដែលគេហៅថាស្រែ១ ៗ មេទ័ពខ្មែរច្រើនប្រើសេះជាជំនិះ ឯយួនច្រើនប្រើក្របី ៗ ការកាប់សម្លាប់គ្នា ច្រើនតែធ្វើឡើងពីរៀងរំលោភលើដីស្រែ ឬដីភូមិ ៗ គេសុទ្ធតែបានណាត់ពេលជាមុន ៗ

ខ្មែរកម្ពុជាក្រោមទាំងអស់ ថ្វីបើគេបានដីជា ដែនដីដែលគេរស់នៅសព្វថ្ងៃនេះ បានធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកដទៃទៅហើយក្តី ក៏គេទុកភូមិស្រុករបស់គេ ជារបស់គេផ្ទាល់ដដែល ៗ ឆ្លងនេះសិទ្ធិ សេរីភាព ក្នុងការរស់នៅរបស់គេក៏គេត្រូវតែការពារជានិច្ច ៗ ព្រោះហេតុនេះហើយក្រោយពីពេលដែលបារាំងបរាជ័យទៅ ខ្មែរយើងនៅទីនោះ បន្ទាប់ពីគេធ្វើបាបជំនួសទាសផ្លូវចិត្ត បន្ទាប់មកមានការព្រាងធ្វើការបន្ត្រាបមក ក៏បានរួមកម្លាំងសាមគ្គីដែលគេបានរក្សាទុកពីយូរយារមកហើយនោះមកប្រើដើម្បីរកសេរីភាពមកវិញ នៅក្នុងឆ្នាំ ១៩៤៥ ដើមឆ្នាំ ១៩៤៦ ៗ ការតស៊ូរបស់បងប្អូនយើងកាលនោះមានសភាពជាអន្តរកប្ប ពីព្រោះកងកម្លាំងសម្រាប់រក្សាការរៀបរយក៏គ្មាន មន្ត្រីផ្លូវការ ឬ មន្ត្រីឃុំ ឬភូមិបានភៀសខ្លួនចោលមុខងាររបស់ខ្លួនអស់ ពោលគឺការសំរេចជីវិតមនុស្សស្លាប់ឬរស់នៅលើដៃអ្នកខ្លាំងពូកែប៉ុណ្ណោះ ៗ

# វិបត្តិសង្គមជាតិ ក្នុងសម័យសង្គ្រាម

ក្នុងឆ្នាំ ១៩៤៥ ជាពិសេសចាប់តាំងពីថ្ងៃទី ៩ មីនា ទៅដល់ដើមឆ្នាំ ១៩៤៦ ស្ថានភាពនៅក្នុងទីប្រជុំជន ទាំងមូលមានការប្រែប្រួលក្រឡាប់ចាក់សំប៉ើងណាស់ ។ ទ័ពអាណានិគមបារាំងចាញ់ជប៉ុន ត្រូវជប៉ុនចាប់ជាឈ្លើយ ។ អ្នករដ្ឋការ ជាពិសេសរាប់ទាំងគង់ទ័ព និងអ្នកបំរើផលប្រយោជន៍បារាំងក៏ត្រូវជប៉ុនចាប់ដាក់គុកនាគារ ឬ ធ្វើបាប ។ លុះមកដល់ដើមឆ្នាំ ១៩៤៦ ទ័ពសម្ពន្ធមិត្តឈ្នះជប៉ុនម្តងវិញ ភាពក្រឡាប់ចាក់ក៏មានឡើងទៀត ។ អ្នកដែលមានការទាក់ទងជាមួយជប៉ុន ទោះខាងផ្លូវនយោបាយ ក៏ដូចក្នុងវិស័យឯទៀត ព្រមទាំងអ្នកស្នេហាជាតិខ្លះទៀតត្រូវទទួលបាបគ្រោះពីបារាំងវិញម្តង ។

ប៉ុន្តែអ្វីដែលជាប្រភពនៃវិនាសកម្ម តាំងពីដំណាច់នោះ រហូតមកសព្វថ្ងៃ គឺចលនានៃយួនវៀតមិញ ។ ចលនា

គស្ទីរបស់ជនជាតិយៀកណាម ចំពោះសាសនានិគមបារាំង នោះ ពិតមែនតែមានកើតឡើងតាំងពីយូរយារណាស់មក ហើយក្តី ក៏ចលនានេះទើបតែនឹងមានបញ្ចេញសកម្មភាពខ្លាំងឡើង ៗ ចាប់តាំងពីមានការប្រែប្រួលដូចជម្រាបខាងលើ ។

ពីហេតុនេះហើយ បានជាក្រោយពីបារាំងចាញ់ជប៉ុនទៅ ពលរដ្ឋយួន ត្រូវធ្វើការហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនៅគ្រប់ច្រកល្ហក ពោលគឺដូចជានៅក្នុងភូមិព្រៃគគយ ស្រុកអណ្ដូងទឹក ខេត្តខ្លាំង ៗ ចលនាយៀកមិញត្រូវរីកធំធាត់ឡើង ហើយការហ្វឹកហ្វឺនរបស់គេ ក៏កាន់តែមានសន្ទុះស្ទុះឡើងជាលំដាប់ ៗ ក្រោយពីយួននិងយួនបង្ហាត់គ្នាគេមក បងប្អូនខ្មែរយើងនៅទីនោះ ក៏ដូចជានៅទីផ្សេងទៀតដែរ ក៏ត្រូវបង្ខំចិត្តចូលហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនឹងគេដែរ ។

ចាប់ពីដំបូងដែលមក ខ្មែរយើងនេះតែមានពិភាល់ចំពោះចិត្តថ្មីរបស់បងប្អូនយួនមកលើយើង ដែលនាំឱ្យយើងខ្វះការគក់ក្តៅ ហើយដណ្ដឹងសួរខ្លួនឯងថា តើការប្រមូលគ្នាមក ជាមកហ្វឹកហ្វឺននេះដើម្បីគេប្រមូលយើងមកក្រុង ទុកមិនឱ្យយើងចេញទៅណាឆ្ងាយ រកទទួលទានដូចធម្មតា ឬ បានជាមានការពិភាល់ដូចនេះ ពីព្រោះក្នុងការហ្វឹកហាត់ គេគ្មានបង្រៀនអ្វីក្រៅពីរៀនដើរ ៗ ក្រោយមកហេតុ

គិតក៏បានលេចចេញម្តងបន្តិចៗ ដែលជាកត្តាមួយជំរុញ ឱ្យខ្មែរមានការត្រិះរិះ

១—មុនដំបូងគេហាមមិនឲ្យកាត់ កាំបិត-ដាវ-ស្នល់ដែក-ក្រចក ដែលពេលមាន ទោះជាឧបករណ៍សំរាប់ធ្វើស្រែក៏ដោយ ។ ក្រោយមកមានកន្លែងខ្លះ គេលើកប្រមូលយករបស់ទាំងនោះដែកម្តង ហើយគេទុកតែកាំបិតធ្វើត្រីមួយប៉ុណ្ណោះ ។

២—ពេលបាត់ដើរលេងថ្ងៃ ខ្មែរនិងយួនតែងលេងសើសាក់គ្នា កើតជាជេរប្រមាថគ្នា ឬវាយតប់គ្នា ពីព្រោះក្នុងពាក្យជេរប្រមាថរបស់គេ ៗ ច្រើនតែនិយាយខ្មែរថាដូចនេះ ដូចនោះ ឬ ដូចជាគេថាខ្មែរឲ្យធ្វើមេក្លូមិចចង់ត្រូវលងជាដើម ឬ ក៏គេថា «យួនក្លូកប្រើហែលខ្មែរម្តងនេះដឹង» ។

៣—ប្លែកជាងនេះទៅទៀត ពេលបាត់រៀនផ្ទះ ៗ ច្រើនតែបញ្ចប់ដោយការវាយតប់គ្នា ពីព្រោះខាងយួន ពេលគេបាត់ដើរយកខ្ទឹមនិងបង្អួរហើង គេច្រើនលើកដើងដាក់ខ្មែរពីចម្ងាយ ដោយទៀតយកថ្នាក់ដើរមួយពីនោះដែកម្តង ។

៤—ដូនកាលពេលបាត់រៀនត្រូវមានតែកុំបិលដែលសល់អំពីដំបាន់ជប៉ុន គេស្ទើរតែទុកចោល គេគត

*ឲ្យខ្មែរទេ បើគេឲ្យ គេទុកឲ្យគ្នាគេយកបានស្រេច បាច់សិន បើសល់ទើបបានមកបងប្អូនយើង ។*

*៥–ក្រៅពីកម្ពុជាសឹងឡាស់លាស់ដូចនេះ ទើបមានការសង្ស័យទៅលើបណ្ដាជនច្រើនខ្លះទៀត ដូចការប្រជុំ គេច្រើនប្រជុំតែជាមួយគ្នាគេ ហើយក្រោយពីការប្រជុំម្ដង ៗ តែងមានហេតុភេទផ្សេងៗ ទៀតកើតឡើង ដូចជាគេឆែកផ្ទះខ្មែរ មានឆែកផ្ទះចីរោយ ផាត់ក្រវើកក្រូកកាយ ដោយគេថា គេការក្ដឹងផែជាសើយ ។*

ចំពោះព្រឹត្តិហេតុដូចនេះ យើងតែងតែពិគ្រោះគ្នា ពីព្រោះយើងមានគំនិតមួយជាប់ជានិច្ច គឺយើងមិនព្រមស្ដាប់ដោយសារគេខ្ទប់ផ្ដើមយើងជាដាច់ខាត ហើយយើងស្រុះស្រួលគ្នាធ្វើបានសម្រេចដូចតទៅនេះ

*១–រកលេសបំបែកការហ្វឹកហ្វឺនទេញពីយួន យើងធ្វើយ៉ាងនេះ ព្រោះយើងត្រូវរៀនវិជ្ជាយុទ្ធសាស្ត្រយួន ។ ការរៀននេះយើងមិនត្រូវការបាត់ទៀតទេ មិនតែប៉ុណ្ណោះ យើងមានគ្នាយើងជាអ្នកចេះវិជ្ជាយុទ្ធសាស្ត្របរិបូណ៌ មានកលល្បិចចិត្តទុកជាសើយ យើងលួចរៀនគុនដាវ - គុនដំបងបន្ថែម ព្រោះបងប្អូនយើងខ្លះមានការជំនាញស្រាប់*

យប់យើងធ្វើសមយុទ្ធកំរៀបការពារភូមិ កំរៀប ទូលប្រយុទ្ធ ជាពិសេសទោះទៀតយើងធ្វើការដាស់ស្មារតីខ្មែរ ឲ្យមានមនសិការជាតិ ដោយយើងល្បួចប្រៀនប្រៀងនគរបាល និងសុវណ្ណភូមិ ។ ក្រៅពីបទពីរនេះយើងឥតគេះអ្វីទៀតទេ គួរឲ្យស្តាយ ។

២—យើងរៀបចំអាវុធរបស់យើង ដូចជាដាវកាប់ស្មៅ មានកន្រ្តុក ដែលយើងទំលាក់ចុះ យើងចាប់លាវាឲ្យត្រង់វិញ កាំបិតចុងស្រួចដែរ ដែកថ្មី យើងផ្លាស់ដាក់ដងវែង ប្រវែងមួយម៉ែត្រ ញួយ ល្មមប្រើការក្នុងពេលប្រយុទ្ធ យុវជនគេមាន កាំបិតស្នៀតគ្រប់គ្នាសម្រាប់ទូលប្រឡុក ។

៣—យើងរៀបចំកន្លែងសម្រាប់លាក់ខ្លួនតាមក្រោយផ្ទះនិងជីកកប់តាងតាមវាលស្រែ ឬក្រោយផ្ទះសម្រាប់លាក់របស់ដូចជា ចានៈ-ឆ្នាំង-មាស-ប្រាក់-អាវ-ខោ ។ល។

៤—យើងបានដើរកត់អ្នកមានទោចក្រយានទុក សំរាប់ប្រើការ ក្នុងការទាក់ទងរបស់យើងក្នុងពេលមានអាសន្ន និងទោចក្រយានណាចាស់ៗគេលែងប្រើការ ទុកសម្រាប់អារយកបំពង់ធ្វើកាំភ្លើងផង ។

វគានការដែលរៀបរាប់មកនេះ យើងពុំមានបំណងអ្វីទៅធ្វើការឈ្លានពានជាតិសាសន៍ណាទេ ប៉ុន្តែយើងគ្រាន់តែធ្វើក្រោមសត្យត្រដេរវិចប៉ុណ្ណោះ ពីព្រោះតាំងពីណាពីណាមក បងប្អូនខ្មែរ និងបងប្អូនយួនតែងរាប់រកគ្នា ខ្មែរ និងយួនមានចំណងមិត្តភាពជាមួយគ្នា ដែលភាសាជនបទស្រុកនោះគេហៅថា ក្លើ ៗ ពេលចូលឆ្នាំយួន-ចិន និងចូលឆ្នាំខ្មែរ មានការអញ្ជើញគ្នាទៅមក មានយួនភាគមិនតិចទេដែលជឿបុណ្យ ជឿបាបដូចយើងដែរ ៗ ការដែលគេប្រែអាកប្បកិរិយាកាយវិការគេ នៅគ្រាចុងក្រោយនេះ យើងមិនទាន់ច្បាស់ថា គេមានបំណងយ៉ាងណាមកលើយើងទេ ប៉ុន្តែយើងបានប្តេជ្ញាចិត្តជាស្រេចហើយថា យើងស្លូតមែន តែយើងមិនព្រមស្លាប់ជាដាច់ខាត ៗ

ថ្ងៃខែ ក៏ចេះតែកន្លងទៅ ព្រឹត្តិការណ៍ជាច្រើនក៏យើងបានឆ្លងកាត់ ប៉ុន្តែថ្ងៃមួយយើងភ្ញាក់នឹងពត៌មានដែលលេចចេញមកពីអ្នកនេសាទ ៗ អ្នកនោះបានប្រាប់បងប្អូនយើងឲ្យប្រុងប្រយ័ត្ន ពីព្រោះយួននៅវត្តព្រះត្រពាំង ក្នុងភូមិសម្តេចចាប់ធ្វើបាបខ្មែរ ដោយគេបាននាំគ្នាកៀងចាប់យកក្របីបងប្អូនយើងរាប់រយក្បាលគ្រប់ៗតែម្តង ម្ល៉ោះហើយមានការកាប់សម្លាប់គ្នាយ៉ាងសាហាវ ៗ អ្នកនាំពាក្យមិនបានបញ្ជាក់

អ្វីក្រៅពីនេះទេ ពីព្រោះយើងមិនបានជួបផ្ទាល់ ។ យើងគឺចាត់គ្នាឱ្យដំណើរដល់បងប្អូនយើងភ្លាម ដើម្បីការពារខ្លួន ប៉ុន្តែសុំកុំឱ្យមានប្រតិកម្មអ្វីឱ្យសោះ ។ យើងបានប្រាប់ដល់ភូមិ ផ្កាគានារ - កំពង់ឈើទាល - ផង់ក្តាង - បឹងព្រលិត - ភូនក្អែក ដើមពោធិ៍ អណ្តូងទឹក ទួនគាង-ផ្កាហៀងជួជាន់ - ដៃអង ផ្តៅពេន ព្រែកទាក ផ្កាឯលិច ផ្កាឯកើត ផ្កាមាន់គោង ដែលសុទ្ធតែភូមិស្តុកស្តម្ភ មានខ្មែរនៅយ៉ាងកុះករ ឱ្យប្រុងប្រយ័ត្នតែដោយស្ងៀមស្ងាត់ គឺឱ្យ «ដាំដើមគមុខផ្ទះទាំងអស់គ្នា» ។ អ្នកនៅមាត់ព្រែកជាប់ទីងសមុទ្រ ត្រូវចាត់ការឱ្យយាម ដើម្បីពិនិត្យទូកក្តោងចេញ-ចូល ។

ប៉ុន្មានថ្ងៃក្រោយមកយើងមានការខ្លត់ជាខ្លាំង ដោយការគិតរាល់របស់យើង ...... បានលេចជារូបរាងឲ្យរស់ក្រៅឡើតគឺនៅក្នុងភូមិកោះប្រហាត - យ៉ាវ៉ាយ - ផ្កាអណ្តាត-ដាំគិន - ដាំយើយ-ព្រែកហ្វូវង់ ឈ្មោះភូមិ ៣ ខាងក្រោយនេះគ្មានឈ្មោះជាខ្មែរទេក្នុងទេត្តកលសារ យួនបានបញ្ចូលបងប្អូនយើងប្រុស ៗ ជាយកទៅទួលស្វាគមន៍ «លោកធំ» ម្ហូបដើម្បីហ៊ីកហ៊ឺន ហើយបញ្ចូលក្នុងរោងដាក់ស្រូវរបស់ជប៉ុន ដុតសម្លាប់ទាំងរស់ ចំនួនប្រហែលរយនាក់ «ត្រាន់តែអ្នកភូមិផ្កាអណ្តាតមួយមានដុតស្លាប់ ៤០នាក់» ។

ថ្ងៃបន្ទាប់មកទៀត ប៊ិននៅផ្សារព្រែកគយ ដែលធ្លាប់

មានការទាក់ទងក្នុងមុខរបររកស៊ីជាមួយយើង បានល្អ ទើបឲ្យយើងថា យួនវាបំផ្លាញវត្តពោធិព្រឹក្សចោលដោយ ថាវត្តនេះខ្មែរតែងយកធ្វើជាកន្លែងប្រមូលផ្ដុំ ៗ តាមគំរោងការសម្ងាត់របស់វា វាមិនមែនដុតវត្តដោយចំពោះទេ តែវាដុតផ្សារដែលនៅជាប់គ្នានឹងកុដិ សាលាទូរ:ដែលសង់ក្នុងវត្តនេះ ដើម្បីឲ្យឆេះក្នុងវត្ត ៗ

សូមជំរាបបញ្ជាក់អស់លោកអ្នកអានថា តាំងពីដើមរហូតដល់ពេលនេះ យើងមិនបានចាំថ្ងៃ-ខែទេ ព្រោះតែស្ថានភាពបង្ខំយើងកាលនោះ ប្រៀបបានទៅនឹងគុក កណ្ដាលទន្លេព្រោះម៉ែ ឪនៅឯភ្នំពេញ ឥតបានដឹងទុក្ខរបស់កូនចៅនៅឯនោះសោះ ៗ បានវង់ ឬ ជុំទៅដែល ហោចណាស់ ក៏អាចបានជាអាផ្ទាកណ្ដាលផែរនោះ យោងតែខ្លួនឯងមិនរួចទៅហើយ តើមានគំនិតឯណាចាំដឹង ថ្ងៃ-ខែទៅកើត ៗ ម្យ៉ាងទៀត ព្រឹត្តិការណ៍អស់នេះកន្លងទៅអស់រយៈពេល ៦៦ ឆ្នាំទៅហើយ គឺចាប់តាំងពីខែធ្នូ ១៨៤៥ និង ដើមឆ្នាំ ១៨៤៦ ម្ល៉េះ ៗ

មកដល់ពេលនេះយើងមិនទាន់ឃើញមានព្រឹត្តិការណ៍អ្វីចេញជារូបរាងនៅឡើយទេ នៅស្រុកព្រែកតយ ៗ ប៉ុន្តែការហ៊ឹកហ៊ឺនទាន់យួន ដូចជាទ្រើលជាងធម្មតា ដែល ជាហេតុមួយនាំឲ្យយើងព្រឹទ្ធិនខ្លួនខ្លាំងឡើង ៗ ៗ

# អ្វីដែលត្រូវកើត ក៏កើតឡើង

ដោយគតិមានពីអគ្គិភ័យ ដែលប្រុងនឹងមានឡើង ដូចជំរាបខាងលើ លោកតា ជាច់ កេង ចៅអធិការវត្តពោធិព្រឹក្ស នៅវត្តចាស់ ក៏បានចាត់លោកតា សារ អ្នកនៅបំរើព្រះសង្ឃក្នុងវត្តនេះ ឱ្យទៅសួរពត៌មានពីអ្នកដឹកនាំចលនាយៀកមិញម្នាក់ឈ្មោះឡុង យួនគាត់ចិន ជាអតីតមេឃុំយួនហៅសាឡុង ផ្ទះនៅមាត់ព្រែក ពីរៀងផុតផ្សារ ដើម្បីលោកនិមន្តទៅបិណ្ឌបាត កុំឱ្យធ្វើយ៉ាងនេះ ។ លោកតាសារ មិនហ៊ានទៅផ្ទាល់ទេ តែបានទៅពឹងបងប្អូនយើងនៅផ្ទាជិតក្បែរវត្តទៅសាកសួរឱ្យ ។ ដោយប្រទះនឹងព្រឹត្តិការណ៍បែបនេះបងប្អូនយើង ១៦ នាក់ ដែលមានឈ្មោះ ស៊ាង ជារម ក៏បានធ្វើដំណើរទៅរកយួន ឡុង ។ គ្រាន់តែចូលដល់របងភូមិ មេយៀកមិញ បាញ់ប្រាវ ៗ តែដោយកុសលមាន បងប្អូន

យើងក្រាបទាន់ហើយស្ទុះរត់ចូលទៅចាប់យួន ទាំងកំរោល ដណ្ដើមយកបានតែការ៉ាភ្លើង ។ ឯមេយៀកមិញ ផាយចេញតាមទ្វារក្រោយបាត់ទៅ ។

ក្រោយពីឧប្បត្តិហេតុមួយនេះកើតឡើង បងប្អូនយើងភាគច្រើនបានបន្ទោសគ្នាថា «ទៅមិនទៅ នាំគ្នាបុកសំបុកស្រាំងឲ្យផ្អើល» ។ នេះជាពាក្យមួយទៀតដែលបញ្ជាក់ឲ្យយើងឃើញថាយើងគ្មានបំណងណាមួយប្រឆាំងដល់ចលនារបស់យួនយៀកមិញនោះទេ ហើយការពិត គឺយួនទេដែលប្រើអាវុធសម្លាប់យើង ពីព្រោះថ្ងៃដែលក្រុមខ្មែរ១៦ នាក់ចូលទៅរកជួបមេយៀកមិញនោះ យើងទៅដោយមានព្រះសង្ឃចង់ជ្រាបការពិត ដើម្បីសុំណូមពរ កុំឲ្យគេ«បំផ្លាញផ្សារ» ។

ចំពោះគ្រោះកាចបែបនេះ អ្នកបន្ទោសគ្នា ក៏នេះតែបន្ទោសទៅ ប៉ុន្តែទាំងអស់គ្នា លែងចូលអ្វីទៀតហើយ ហើយក៏ចាប់ផ្ដើមប្រដាប់កាំបិត - ពូថៅគ្រប់គ្នាដោយចំហ ហើយចាត់គ្នាយាមគ្រប់ច្រកចូលភូមិ និងចាត់គ្នាឲ្យស្រង់គតិមានខ្លះដែលបានទទួលនូវគ្រប់ចិត្តខ្វែង ។

នៅថ្ងៃទី ២០ ធ្នូ ១៩៤៥ មេយៀកមិញឈ្មោះ ឡុង ដែលរត់ចោលការ៉ាភ្លើងដូចជំរាបខាងលើ បាននាំគ្នាប្រហែល ៥០ញាយនាក់មកពីកោះកុងដីម នៅមាត់ទន្លេមីចាញ់ ហៅទន្លេឯត្បូង បំណងវាយប្រហារបងប្អូនយើងនៅភូមិព្រែក

ជាក ៗ ប៉ុន្តែគ្រាន់តែមួយម៉ោងក្រោយពីចុះពីទូកសមុទ្រ ឡើងដល់ដីលើគោកមក ក៏ត្រូវបងប្អូនយើងប្រមូលគ្នាដេញវាយប្រហារជាប់ផ្ទួនរំណាលទៅតាមវាលស្រែ ៗ យួនយៀកមិញដែលនៅសល់ពីស្លាប់ទាំងប៉ុន្មាន ក៏រត់ឡើងទូកធ្ងន់ទៅរកដីរបស់វានៅឯកោះកុងមីមនោះអស់វិញទៅ ៗ នៅថ្ងៃនោះយើងមានទទួលខូចខាតតែបន្តិចបន្តួច ហើយថែមទាំងយកបានអាវុធប្រយាប់មួយដើមទៀតផង ក្រៅពីគ្រាប់បែកដៃ និង ធ្នូ ស្នា មួយចំនួនធំ ៗ

បន្ទាប់ពីព្រឹត្តិការណ៍នៅភូមិព្រៃគគាកដែលនៅឆ្ងាយប្រហែល ៥ គ.ម ពីភូមិព្រៃគគយមកបងប្អូនយើងបានផ្អាកកិច្ចការទាំងអស់ ហើយតែងប្រមូលផ្តុំគ្នាជាក្រុមតូច - ធំ តាមភូមិខាងនាក៏មាន នៅតាមព្រែកចូលផ្សារក៏មាន តាមវត្តអារាមក៏មាន ដើម្បីប្រជុំគ្នាការពារខ្លួន ឬធ្វើអន្តរាគមន៍ ៗ

រាំងថ្ងៃ ២៥ ធ្នូ ១៩៤៥ យួនយៀកមិញមួយក្រុមចំនួន ៣០ ក្នាយខាត់ប្រដាប់ដោយធ្នូ ស្នា កាំបិតហាន់ដើមចេកស្ទួ និងកាំភ្លើងប្រយាប់ខ្លះ បានត្រូវបងប្អូនយើងដែលយាមនៅតាមផ្លូវចូលទៅផ្សារព្រៃគគយក៏ទូដាប់បំរុងដេកអាវុធ ៗ ប៉ុន្តែដោយមេយៀកមិញបានឱ្យដឹងថា គោលបំណងរបស់ក្រុមគេដែលចូលមកនេះគឺដើម្បីចង់ជួបថ្វាយបង្គំលោកតា ចាប់-គេជ នៅអធិការវត្តពោធិព្រឹក្ស ដើម្បីសុំឱ្យលោកជួយ

ធ្វើការសម្រុះសម្រួលកុំឲ្យខ្មែរ-យួន ឈ្លោះគ្នាតទៅទៀត ។ ដោយយើងឃើញថានៅក្នុងផ្ទៃចក្រយួនទាំងនោះ មានព្រះសង្ឃខាងមហាយានមួយអង្គ និមន្តដូនដំណើរមកជាមួយ ដែលយើងត្រូវតែទទួលស្គាល់ថា ជាសញ្ញាសន្តិភាពនោះ យើងក៏បានចាត់គ្នាឲ្យនិមន្តព្រះសង្ឃ ៣ អង្គនៅវត្តព្រហ្ម-វិហារ ហៅវត្ត គកធំឈើទាល គឺព្រះភិក្ខុ ថាច់ ចយ ព្រះភិក្ខុ លី ផា និងព្រះភិក្ខុ សុង ផា (១) ជាតំណាងព្រះសង្ឃនិងបងប្អូនយើងនៅត្រើយគោក ដើម្បីធ្វើការចរចា ជាមួយយួន ។ ក្រោយពីយើង និងព្រះសង្ឃ បានធានាអះអាងដល់ក្រុមយួនថាគោលដៅរបស់យើងគឺសេចក្តីសុខ ខ្មែរ និង យួន ត្រូវទុកគ្នាជាបង-ប្អូនដែលធ្លាប់មុននោះមក និងមុនគេដកថយទៅកុងដីមវិញ យួនបានសុំនិមន្តព្រះសង្ឃទាំង ៣ អង្គនោះ និមន្តទៅជាមួយគេ ដើម្បីជាកិច្ចធានាដល់សេចក្តីសុខរបស់គេនៅតាមផ្លូវ ។ ដោយចង់ដឹងពីគោលបំណងពិតរបស់វៀតមិញ និងចង់ដឹងពីស្ថានការណ៍នៅកុងដីមផង និងតាមសេចក្តីយល់ស្របពីលោកតា ថាច់ គេង ព្រះសង្ឃទាំង ៣ អង្គក៏បានប្តេជ្ញាព្រះទ័យ និមន្តដូនដំណើរយួនទៅវិញ តាម

---

*(១) គួរចំណាំថា: អតីតព្រះភិក្ខុ សុង ផា បានចាកសិក្ខាបទហើយ សព្វថ្ងៃធ្វើជាយុទ្ធជនទៅក្នុងកងឯកភាពមួយ ក្នុងកងទ័ពជាតិ ប៉ុន្តែមិនច្បាស់ទីកន្លែង ។*

សេចក្ដីសុំរបស់គេ ។ សូមជំរាបថា ពេលក្រុមយួនដកថយទៅវិញភ្លាមក៏ស្រាប់តែឃើញគណរដ្ឋយួននៅផ្សារព្រែកគយរាប់ម៉ឺននាក់បានដឹកកូន ជញ្ជូនចៅ គៀសខ្លួនចេញពីផ្សារព្រែកគយទៅតាមទ័ពយួនដែរ ដែលជាហេតុមួយនាំឲ្យយើងដឹងថា យួនដែលចូលមក ៧០ ម៉ឺននាក់ធ្វើជាមកចរចាជាមួយយើងនោះ ការពិតគឺគេមករំដោះជនជាតិយួនដទៃទៀតឲ្យថយចេញពីផ្សារព្រែកគយ ដើម្បីគេនាំយកមកវាយកម្ទេចខ្មែរយើងនៅថ្ងៃក្រោយប៉ុណ្ណោះ ។ រីឯការចរចារវាងគេនិងយើង ជួបជំរាបទាន់ហើយ ក៏ មិនឃើញមានព្រះសង្ឃយួនគ្រាន់តែជាលេសសំរាប់គេដោះដៃ ឲ្យផុតពីការឡោមព័ទ្ធរបស់ក្រុមអ្នកយាមខ្មែរយើង តែប៉ុណ្ណោះ ។

ពេលទៅដល់ភូមិដីម មេក្រុមយួនបានយកព្រះសង្ឃទាំង ៣ អង្គដែលមិនព្រមទៅជាមួយ ទៅគង់ក្នុងរោងដាក់ជីក្រើមួយ ឃ្លាតឆ្ងាយពីផ្ទះយួនឯទៀត លុះមួយស្របក់ក្រោយមក ក៏ស្រាប់តែមានគណរដ្ឋយួនរាប់រយនាក់ មកនិយាយដៀមដាមដាក់ព្រះសង្ឃ ធ្វើឲ្យព្រះសង្ឃកើតក្ដីរន្ធត់ជាខ្លាំង ។ បន្ទាប់មកទៀត មេទ័ពយួននៅទីនោះ បានយកកាំភ្លើងខ្លីមួយដើមមកបោះលើតុ រួចគេនិយាយទៅកាន់ព្រះសង្ឃដោយពាក្យបោះបញ្ជោះថា៖ ‹‹បើអ្នកណាហ៊ានធ្វើអីលោក លោកនេះបាញ់ស្រាប់ បាញ់បំបែកក្បាលក៏ទៅ›› ។ ប្រ

ហែលជាម៉ោង១២យប់ថ្ងៃនោះ មេឃ្លួនបាននាំព្រះសង្ឃទៅមើលឃ្លាំងអាវុធដែលឃើញមានកាំភ្លើងតូច-ធំ ដាក់តំរៀបគ្នាជាច្រើនជួរ ប៉ុន្តែមេឃ្លួនក៏បានហាមមិនឱ្យព្រះសង្ឃនិមន្តទៅជិតឃ្លាំងនោះទេ ដោយអាងថាក្រែងបណ្តាលឱ្យគ្រាប់បែកដែលស្តុកជាមួយនោះ ដែរផ្ទុះ អាចបណ្តាលឱ្យមានគ្រោះថ្នាក់ ។ត្រង់នេះព្រះសង្ឃអាចឃើញច្បាស់ណាស់ ថាសុទ្ធតែកាំភ្លើងឈើលីងតែទាំងអស់

លុះព្រឹកឡើង មេទ័ពឃ្លួនបានដោះលែងព្រះសង្ឃមួយអង្គឱ្យនិមន្តយកសំបុត្រ មកប្រគេនលោកតា ថាច់ គេង ចៅអធិការវត្តព្រៃគគយ សុំឱ្យលោកតានាំអះអាងជាលាយលក្ខអក្សរ កុំឱ្យខ្មែររករឿងនិងឃ្លួនទៀត ។ ក្រោយពីលោកបានបំពេញតាមបំណងរបស់វាជាលើកទីមួយហើយ ថ្ងៃបន្ទាប់មក វាបានចាត់ព្រះសង្ឃមួយអង្គឱ្យនិមន្តយកសំបុត្រវាមកទៀត និយាយតែរឿងដដែល ៗ លោកតា ថាច់ គេង មិនទាន់ទាំងបានឆ្លើយតបសំបុត្រទីពីរនេះផង ក៏ស្រាប់តែឃើញព្រះសង្ឃអង្គទី ៣ និមន្តមកដល់ទៀត ដើម្បីរឿងដដែលទៀត ៗ មកដល់ត្រង់នេះ យើងគ្មានត្រូវការអ៊ីចឹងចាញ់បោកឃ្លួនជាលើកទីពីរទៀតទេ ។ ដោយហេតុហ្នឹងហើយ បានជាយើងផ្តាច់ការទាក់ទងត្រឹមនេះសិន ដោយសារថាព្រះសង្ឃដែលជាប់ក្នុងកណ្តាប់ដៃវានោះ បានរួចមក

វិញហើយ ត្រូវការអ៊ីចិនចាត់ឲ្យស៊ីវិលទៅទៀត ។ គេលែងព្រះសង្ឃ ពីព្រោះគេដឹងថាគេស្អិតនៅត្រង់ចំណុចខ្សោយ ។

✲❦✲

# អ្នកហ៊ានស្លាប់
# ច្រើនតែជាមិនស្លាប់

ដោយសារយួនយៀកមិញបានបញ្ចេញបំណងពិតរបស់គេឲ្យយើងឃើញច្បាស់ដូចនេះ យើងក៏បានចាត់ចែងការសព្វគ្រប់ដើម្បីទប់ទល់ ។ ដំបូងយើងបានប្រជុំគ្នារើសអ្នកដឹកនាំចលនារបស់យើង ដោយមានលោកតា ថាច់ ហ៊ុម អាចារ្យវត្តពោធិព្រឹក្ស លោកតា ឡាំ ណុប កសិករខិនបង ប្អូនយើងខ្លះទៀតចូលរួមផង ។ មតិអង្គប្រជុំបានមូលមកលើ ចៅដោយ ផាត់ ពីព្រោះជាកូនក្រោលបន្ទាលស្និទ្ធស្រាប់ ។

បន្ទាប់មកទៀត យើងបានធ្វើការបញ្ជាក់ទៅលើខ្សែបន្ទាត់របស់ចលនាយើង ពីព្រោះយើងជាជនភាគតិចនៅក្នុងកណ្ដាប់ដៃគេ ត្រូវឲ្យមានខ្សែបន្ទាត់ដែលមិនអាចនាំយើងទៅរកក្ដីវិនាសបានទៅថ្ងៃក្រោយ ។ ក្រោយពីបានជជែកគ្នាមួយលើក ជាពីរលើកមក ទើបដើម្បីឲ្យមានការធានាពីមជ្ឈដ្ឋានព្រះសង្ឃផង យើងក៏បាននិមន្តលោកតា ថាច់ -

ពេជ  ទៅអធិការវត្តពោធិព្រឹក្ស និមន្តចូលរួមប្រជុំដើម្បីជាទីប្រឹក្សា ។ អង្គប្រជុំដ៏សម្ងាត់នេះ បានសំរេចមាគ៌ារបស់យើងផ្លូវតទៅនេះ ៖

១— ជៀសវាងជាដាច់ខាត កុំបង្ករឿងមុន

២— ឆ្លៀតគ្រប់ឱកាសល្អ ដើម្បីធ្វើឲ្យគេអាណិតយើង

៣— ប៉ុន្តែអ្វីដែលយើងមិនព្រមទទួល គឺកំហុសដែលគេដាក់មកលើយើង ដោយពីប៉ុន្មានថ្ងៃមុននេះ គេចោទថា យើងនាំគ្នាបះបោរប្រឆាំងនឹងវៀតមិញ ដើម្បីឲ្យបារាំងចូលមកត្រួតត្រាបានស្រួល ។ មានជូនកាលគេឲ្យគ្នាគេមកនិយាយភរយើងថា គេអាណាស់ប្រសិនបើបងប្អូនខ្មែរយកដីកម្ពុជាក្រោមឲ្យខ្មែរភ្នំពេញត្រួតត្រាវិញ គឺព្រោះស្រួល « រកស៊ី »... ។

ដោយមានជំនឿទៅលើព្រះពុទ្ធសាសនាដ៏មោះមុតផង ដើម្បីលើកទឹកចិត្តអ្នកតស៊ូរបស់យើងផង យើងក៏បានបួលគម្ពីរ "បាក់គម្ពីរ" យើញត្រង់សុគត ជាអ្នកគោរពព្រះសមណគោត្តម និងករហាទិន ជាអ្នកគោរពពួកព្រាហ្មណ៍នៅក្នុងល្បិចកលដែល ករហាទិនប្រើដើម្បីធ្វើគតព្រះពុទ្ធនេះបានផលផ្ទុយទៅវិញ រូបសេចក្តីមកថា ការតស៊ូរបស់យើងមុខតែមានជោគជ័យ ។

សូមជំរាបអស់លោកអ្នកអានថា តាំងពីមានរឿងទាក់ទង

ទីធំព្រះសង្ឃ មកដល់ពេលយើងរៀបចំផ្លូវដំរាបខាងលើ គាត់ស្ងប់ស្ងាត់ផ្លូវជាមានឡើងវិញដែរ ៗ ស្រាប់តែរាំង ថ្ងៃ ៣០ ធ្នូ ១៩៤៥ មានយួនមួយក្រុមប្រហែល ១០០ បាយនាក់ ឆ្លងពីកោះកុងដីមមកទៀត មកឡោមព័ទ្ធភូមិបង-ប្អូនយើងនៅក្នុងក្ដុកបំរុងសាងវិនាសកម្ម ៗ ប៉ុន្តែបង-ប្អូនយើងបានប្រមូលគ្នាប្រយុទ្ធជាមួយខ្មាំងយួន មានកាំភ្លើងបាញ់សត្វ ៦ ដើម ក្រៅពីធ្នូ-ស្នា ខ្មែរយើងគ្មានអាវុធអ្វីក្រៅពីកាំបិត-ដាវ-លំពែង ផ្លូវនេះខ្មែរយើងត្រូវប្រើកាំងតែពីអំបែងពាង-ដប-ដុំអិដ្ឋ គ្រវែងទៅកយួនតាំងពីព្រឹម ខាងសាយតាំងពីម៉ោង ១៦ រហូតដល់ម៉ោង ១៧ ៗ នៅម៉ោងនេះ ខ្មែរយើងមួយក្រុមបានបញ្ឆោតខ្មាំង ហើយលបឆ្លងព្រែកទៅប្រឡូកជាមួយ ធ្វើឲ្យយួនបាក់ទ័ព ៗ ថ្ងៃនោះយើងស្លាប់ ២ នាក់ យួនស្លាប់ប្រហែល ៦ នាក់ ៗ

ចំពោះព្រឹត្តិហេតុថ្មីនេះ យើងលែងសង្ស័យអ្វីទៀតចំពោះពាក្យផ្អែមល្ហែមផ្លូវដំរាបខាងលើនេះទៀតហើយ ៗ ប៉ុន្តែយើងក៏ឥតមានផ្ដើមធាកប្រយុទ្ធអ្វីជាថ្មីទៀតដែរ ៗ ហើយយើងមានការប្រុងប្រយ័ត្នទ្វេ មួយជាដប់ ៗ

ដើម្បីជាការងាយស្រួលក្នុងការតស៊ូរបស់យើង យើងបានតាំងសេនាធិការដ្ឋានរបស់យើងនៅផ្ទះលោកតា អតីតចៅសង្កាត់ ឡាំ ឈើន ស្ថិតនៅក្រោយសាលាសង្កាត់ព្រែក

គយ ៗ បានជាយើងយកកន្លែងនេះ ធ្វើជាកន្លែងចាត់ការរបស់យើងដោយសារកន្លែងនេះមានស្ពានមួយ ដែលយើងត្រូវការពារ ហើយជាកន្លែងដែលព្រែកបែកជាបី ៖ មួយទៅបឹងព្រលិត-ផងក្ដាង-ដើមពោធិ-ភូនព្រែក- មួយទៀតទៅខាងកើត-ទៅភូមិកំបុត-ព្រែកទីបីបែកទៅរកផ្សារព្រែកគយទៅផែនង- ចាក់ទង- បាយកៅ និងទីរួមខេត្តឃ្លាំង គោលគឺជាចំណុចមួយសំខាន់ខាងផ្នែកយុទ្ធសាស្ត្រ ៗ

បើគេឈរលើស្ពាន មើលទៅទិសខាងត្បូង គេនឹងឃើញវាលស្រែល្វឹងល្វើយជាប់គន្ទុយភ្នែកចំនួនរាប់ម៉ឺនហិកតា នៅចំហៀងខាងស្ដាំវាលនេះ មានព្រែកមួយ ហៅព្រែកបឹងព្រលិត ៗ បង-ប្អូនយើងបានតាំងលំនៅឋាន នៅតាមមាត់ព្រែកខាងឆ្វេងនៃ រីឯពលរដ្ឋយួននៅក្រោយខាងស្ដាំ ៗ នៅចុងព្រែកខាងជើង មានវត្តខ្មែរមួយ ហៅថាវត្តភូនព្រែក ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្សារភូនព្រែក ៗ ចម្ងាយពីស្ពានវត្តភូនព្រែក ប្រហែល ១០ គ.ម ប៉ុណ្ណោះ ៗ ភូមិបង ប្អូនយើងនៅទីនោះ សុទ្ធសឹងជាភូមិស្ដុកស្ដម្ភ មានដើមដូង-ស្លា-សន្ដែ-អំពួរ-ស្វៃ-ស្ដៅ-ចេក-ស្វាយ ដុះពាសពេញ ជាទីសែនមនោរម្យ ៗ

រំលងថ្ងៃទី ២ មករា ១៩៤៦ ពេលដែលសមាជិកសេនាធិការស្រស់ស្រូបរួចផ្ទះរៀងរាល់ថ្ងៃដែរ យើងតែងទៅ

ផងដែរលើកទឹកចិត្ត បង ប្អូនយើង ដែលយាមនៅលើស្ពាន
ដើម្បីបំភ្លេចកិច្ចកន្ទល់ទាំងឡាយ ។ មួយសន្ទុះក្រោយ
មក វេលាម៉ោង ៧ កន្លះ ពួកយើងបានទាញអារម្មណ៍
យើងឲ្យផ្តោតទៅលើដុំផ្សែង ដែលហុយផ្ដោលទៅលើមេឃ
នៅម្តុំវត្តកូនក្អែក ហើយដុំផ្សែងដទៃទៀត បានហុយឡើង
បន្តបន្ទាប់គ្នា ដែលញាំងឲ្យយើងដឹងថា វិនាសកម្ម បាន
ធ្លាក់មកលើបង ប្អូនយើងទៀតហើយ ។ ពេលជាមួយគ្នា
នោះ អ្នកនាំសារក៏បំផាយសេះមកដល់ ហើយប្រាប់ថាយួន
ប្រហែល ១០០ បាយនាក់ ខ្លះជិះទូក ខ្លះដើរ បានចូល
មកផុតវត្តដើមក្អែក និងផុតផ្ទះ បង ប្អូនយើងអស់ជាច្រើន
ខ្នង ។ អ្នកនាំសារបានបញ្ជាក់ទៀតថា ៖ ទូកយួន ដែល
មានយួន ប្រដាប់អាវុធជិះក្នុងនោះ បានបើកចូលក្នុងព្រែកបឹង
ព្រលឹត បណ្តើរ បាញ់បណ្តើរ ធ្វើឲ្យបង ប្អូនយើងភៀស
ចេញពីភូមិ ដើម្បីទុកឲ្យគ្នាវាដើរផុតផ្ទះតាមក្រោយ ។
និងគ្នាវាមួយចំនួនទៀត តាមជួយការពារផ្ទះយួន ដែលសង់
តាមមាត់ព្រែកខាងស្ដាំ ដូចជារាបខាងលើ ។

ក្រោយពីបានឮស្នូរស្គរជំដាតសញ្ញាមក បងប្អូន
យើងប្រហែល ២០០ នាក់ បានមកដល់មុខគេ ប្រដាប់
ដោយ ដាវ-ស្នា-លំពែង-ព្រួញ-កាំបិតផងវែងនៅនឹងដៃ
ស្រាប់ ។ ក្រោយពីយុទ្ធជនយើងដឹងច្បាស់នូវស្ថានការណ៍

និងវិធីទម្លាប់ថ្នាំងមក និងដោយសារសំណូមពរដោយទទូចពីគាត់ផង យើងក៏បានប្រគល់ភារៈដឹកនាំទ័ពជូនលោកតាឡាំ ណុប «អាយុ ៥០ ញួយឆ្នាំ» ។

គឺនៅពេលនេះហើយដែលបង - ប្អូនយើងបានឃើញទង់ជាតិរូបប្រាសាទជាលើកទីមួយ ដែលសេនាធិការយើងទើបនឹងធ្វើរួច ហើយប្រគល់ជូនលោកតា ណុប លើកទ័ពទៅរកថ្នាំង ។

ក្រោយតែប្រហែលមួយម៉ោង ពីទ័ពយើងចេញដំណើរទៅ ភ្លើងដែលឆេះតែរំកិលដីតមកនោះ ក៏ឆេះថយទៅវិញ ដែលជាហេតុប្រាប់ឲ្យយើងដឹងថា ខ្មាំងមានជោគជ័យហើយ ដោយគេបានដុតផ្ទះយួន ដែលរាយតាមមាត់ព្រែកទាងស្ពាននោះម្តងវិញ ។

សូមបញ្ជាក់ថា ក្រោយពីទ័ពយើងចូលនៅផល់ យើងគ្រាន់តែចែកគ្នាឲ្យទប់ទល់ថ្នាំងបន្តិចបន្តួច ដើម្បីឲ្យយួននិងយើងផាប់ដៃគ្នាសិន ហើយយើងចាត់ឲ្យគ្នាយើងមួយពួកទៀត កាប់ដើមឈើដែលដុះតាមមាត់ព្រែកស្រាប់នោះ រំលំទទឹងព្រែកដើម្បីឃាំងទូកយួន កុំឲ្យរត់ធ្វើចលនាទៀតកើត និងបន្ទំយួនដែលនៅក្នុងទូកនោះឲ្យឡើងគោកផង ដើម្បីកុំទចក់ជាក្រោយ ៗ ហេតុដូចនេះហើយបានជានៅពេលដែលទឹកនាច ថ្ងៃទឹកស្រកចុះរួច ខ្មាំងនៅក្នុងទូកដែល

ត្រូវមាត់ច្រាំងព្រែកចាំងក្អែក មើលមកយើងមិនឃើញ បានឱកាសញ្ញាំងយើងឱ្យលួចទៅជិតទូកបាន ហើយគប់ទូកនោះជឹងផ្ទុំឈើ-ផុំដី-គ្រាប់បែកស៊ុមធំតូច ៗ យួនទ្រាំមិនបានក៏រត់ចោលទូក គឺនៅពេលនោះហើយដែលធាក់ប្រយុទ្ធដ៏សាហាវរវាងខ្មែរ និង យួនបានកើតឡើង ៗ នៅពេលវាបាក់ទ័ព យុទ្ធជនយើងបានដេញកាប់សត្រូវទាំងស្រស់ ដេញប្រហែល ២គម. យួនអស់គ្រាប់ ខ្មែរដេញយួនរហូតផ្សារភូនក្អែក ចម្ងាយពីកន្លែងប្រយុទ្ធដំបូងប្រហែល ៤គម. ៗ ត្រង់នេះយើងសូមបើកវង់ក្រចក ដើម្បីសំដែងសេចក្តីសោកស្តាយ ដោយយុទ្ធជនដ៏ក្មេងខ្ចីម្នាក់ឈ្មោះ ថាច់ វង់ ត្រូវជាក្មួយលោកតា ថាច់ ពេជ ដែលត្រូវរបួសនៅក្រោយផ្សារភូនក្អែក ហើយត្រូវយួនអារកបាន ដោយគ្នាយើងរត់ទៅជួយមិនទាន់ ៗ

នៅពេលដែលទ័ពយើងត្រឡប់មកវិញ ដំណើរពីយួនផុតវគ្គភូនក្អែក បានហិចហើរលាន់ឮខ្ទរទៅគ្រប់ទិសទី ដូចស្នូរផ្គរលាន់ ៗ នេះជាកំហុសមួយធំ ក្រៃណាស់ ដែលយួនបានប្រព្រឹត្តមកលើខ្មែរ មកលើសាសនាដែលខ្មែរខ្ញូរទៅគោរព ៗ ផ្ទះខ្មែរនេះ ខ្មែរឥតគិតទេ ប៉ុន្តែអ្វីដែលខ្មែរគោរព ហើយត្រូវគេធ្វើឱ្យអបរស្មី ខ្មែរឈឺចាប់រកទីបំផុតគ្មាន ៗ

ដោយសារតែក្តួនក្អែកត្រូវបំផ្លាញ ខ្មែរ និង យួន បើកទាក ប្រយុទ្ធកាប់សម្លាប់គ្នាសឹងគ្រប់ទិសទី សាយភាយរហូតទៅដល់ទីប្រជុំជន បាយនៅ-ចាក់ទ្រឹង ។ល។ ដែលនៅឆ្ងាយពីព្រែកគយប្រហែល ២០ គ.ម ។ នៅស្រុកខ្វះនៃខេត្តពលសារ ក៏ដូចនេះដែរ ។ ខ្មែរ និងយួន បានចោទគ្នាទៅវិញទៅមកតែអ្វីដែលយួនមិនព្រមរក គឺឫសគល់ គឺប្រភព គឺមេភ្លើងដែលញុះញង់ខ្មែរ និងយួនឲ្យនិយាយស្តាប់គ្នាលែងបាន ដូចបុរាណលោកប្រៀបទៅដើមចេក និងក្របីផ្លោះឯង ៗ

ហេតុដូចនេះហើយទើបរៀងរាល់ថ្ងៃ គេតែងឃើញអត្តឃាតគ្រប់ទិសទី ៗ ឯនេះ ខ្មែរផុតដុះយួន ៗ ឯនោះយួនបំផ្លាញគេហដ្ឋានខ្មែរ ៗ នៅតាមព្រែក ពីព្រែកគយ ទៅបាយនៅ បណ្តាយប្រហែល ២០ គ-ម ប៉ុណ្ណោះ គេឃើញមានសាកសពខ្មែរ និងយួន អណ្តែតរង្គរណែលរាប់រយ ៗ នៅតាមព្រែកដទៃទៀត ក៏មិនខុសគ្នាប៉ុន្មានពីព្រែកនេះដែរ ៗ អ្នកស្រុកមិនហ៊ានទទួលទានទឹក តមមិនយកអន្ទង់-បង្កង-បង្គា-ត្រី-ក្តាមសមុទ្រ ។ល ។ ធ្វើអាហារទេ ៗ

ក្រុមយើងតែងលើកគ្នាទៅជួយនៅកន្លែងណាដែលត្រូវការ ៗ

សូមជំរាបថា មកដល់ពេលនេះ យើងមានតែការបិត-ព្ធទៅ ដើម្បីការពារខ្លួន ៗ ប៉ុន្តែអ្វីដែលជាកម្មវិធីកំពូល

របស់យើង គឺជំនឿលើខ្លួនឯង លើការរួបរួមគ្នា លើការចេះស្តាប់គ្នា ចេះគោរពបទបញ្ជា មានវិន័យថ្លៃថ្នូរ ។ ឧទាហរណ៍ ពេលប្រុស ១ ទៅប្រចាំការនៅសេនាធិការដ្ឋាន ដែលមានចំនួនរាប់ពាន់នាក់រៀងរាល់ថ្ងៃ ស្រី ១ ណាដែលលែងទៅបាន ។ ទៅជួយរៀបចំបាយទឹក ជូនយុទ្ធជនគ្រប់ពេលវេលា ។ ពិតមែនតែយើងគ្មានប្រាក់សំរាប់ចំណាយ ប៉ុន្តែបាយ ម្ហូប មិនចេះខ្វះ ពីព្រោះម្នាក់ ១ ដែលអញ្ជើញមកប្រួបរួមកម្លាំងគ្នានោះក្នុងឋានះជាយុទ្ធជនក្តី ជាអ្នកមានមុខការផ្សេង ពីនេះទៀតក្តី មិនដែលអញ្ជើញមកដៃទទេទេ ។ អ្នកក្រីក្រក៏សុខចិត្តចូលរួមក្នុងការប្រយុទ្ធរួមគ្នា ជាពិសេសពួក ១ ដែលមាន វ័យចាស់ទៅហើយ ក៏បានមកជួយរែកទឹក ពុះឧសបិតចង្កើះ លើកដាក់របស់របរផ្សេង ១ ។ ក្រៅពីជំនឿលើខ្លួនឯង យើងមានជំនឿទៅលើព្រះពុទ្ធសាសនាមុតមាំណាស់ ។ ហេតុដូចនេះហើយបានជានៅពេលមុនចេញទៅបំពេញសកម្មភាពម្តង ១ អ្នកដែលចេះធម៌ព្រះពុទ្ធតែងសូត្រប្រកព្រំជូនដល់យុទ្ធជនយើង «អស់ទឹកទាំងពាង» ធម៌ដែលយកមកប្រើ គឺធម៌ឥតិបិសោ . . . . . ។

កាំភ្លើងដែលយើងយកបានពីខ្មាំងបីដើម មានមួយដើមបាក់ពេលប្រយុទ្ធគ្នា ពីរដើមទៀតជាកាំភ្លើងប្រមាញ់ យើងទុកសំរាប់តែបាញ់ពេលដោះកុងម្តង ១ ឬ បាញ់សំឡុត

សត្រូវព្រោះមិនសូវមានគ្រាប់ ។ ហើយកាលនោះ នៅពេលប្រយុទ្ធគ្នាម្តងៗ យួនក៏ពុំសូវមានអាវុធអ្វីក្រៅពីមុស្គែតុង កាំភ្លើងប្រមាញ់ និងព្រួញ-ស្នា កាំបិតស្នៀត ដែលយួនហៅថា កាំបិត "យួគិច" ខុសគ្នាពីខ្មែរយើងដែលប្រើតែព្រនង់មានកាំបិតខាងចុងម្ខាងជាប់ - លំពែង - កាំបិតវែង-ស្ន-ច្បូក និងកាំបិតយួគិចដែរ គ្រាប់បែកដៃធ្វើពីស៊ីម៉ង់ត៍មានបន្ទាដែកគោល យើងធ្វើបានខ្លះទុកប្រើការពេលប្រឡូកគ្នាៗ កាំភ្លើងអាយ ដែលគេធ្វើដោយអារត្តកង់នោះ យើងធ្វើសម្រាប់តែយកស្នូរ ឱ្យតែប៉ុណ្ណោះ «ដូចយៀកកុងភ័យញោតដែរ» ។

ការមានរបៀបលើសត្រូវ ដែលនាំឱ្យយើងរួចពីស្លាប់ រហូតមកដល់ពេលនេះ គឺស្ថិតនៅលើវីរៈភាពដែលបងប្អូនយើងមាន ។ អ្នកដឹកនាំទ័ព ទោះចាស់ក្តី ក្មេងក្តី ច្រើនតែជាអ្នកហ៊ានរហូត រីឯយុទ្ធជនទៀតសោត មានការធ្លាត វាងវៃហួសពីការស្មាន ។

ដូចនេះអ្វីដែលយើងនៅខ្វះ គឺខ្វះសេចក្តីសង្ឃឹមទៅលើអានាគតរបស់យើង បើយើងហើយនៅចាំតែរង់ដូចនេះតទៅទៀតមិនបង្ហាញឱ្យសត្រូវរបស់យើងឃើញ ស ឃើញខ្មៅម្តងទេ ។

ហេតុនេះហើយ បានជាក្រោយពីមានការប្រជុំពិគ្រោះយោបល់គ្នាដោយសម្ងាត់មក យើងបានសម្រេចថា ត្រូវតែស្វែងរកទិញអាវុធ ឱ្យបានយ៉ាងតិច ១០ ដើមឲ្យ ដើម្បីសម្រេចគោលដៅរបស់យើង ឱ្យទាន់ពេលវេលា ពីព្រោះស្រែដែលទុំក្រហមសឹងពេញវាល យើងប្រាកដមិនទាន់បានកាត់កណ្តាលនៅឡើយនេះម៉្យាង ម៉្យាងទៀតយើងត្រូវគិតដល់ផ្លូវស្រែខាងមុខ និងការរៀបចំសង់លំនៅដ្ឋាន និងភូមិដែលត្រូវនេះ ឬត្រូវបំផ្លាញឡើងវិញឱ្យបានមុនរដូវវស្សាជាចាំបាច់ ។

ដោយភារៈកិច្ចរកកាំភ្លើងនេះ ត្រូវធ្លាក់មកលើជីដោយ ផាត់ យើងក៏បានចេញដំណើរ វេលាថ្ងៃ ១២ មករា១៩៤៦ ឆ្ពោះទៅទីរួមខេត្តឃ្លាំង ជាមួយយុវជន ៦ នាក់ ក្នុងចំណោមនោះ មានលោក ឡាំ ព្រែត ជាអតីតពលបាលទោ ហៅជីដោយ ព្រែត ទៅជាមួយដែរ ។

តាមផ្លូវពីព្រែកគយ ទៅដល់ភូមិចាក់ទឹង ចម្ងាយប្រហែល ១៥ គ.ម ពុំមានអ្វីនាំឱ្យបារម្ភទេ ប៉ុន្តែចាប់តាំងពីចាក់ទឹងទៅ ជាតំបន់មានសុទ្ធតែពលរដ្ឋយួននៅ ដូចជាទីប្រជុំជនបាយនៅ និងភូមិជាច្រើនពីបាយនៅ ទៅទីរួមខេត្តឃ្លាំងជាដើម ។ ដូចនេះយើងត្រូវផ្សងព្រេងដោយកាត់តាមវាលស្រែ សសៀរតាមជាយភូមិយួនតូចៗ ដែល

មានចាប់ពីត្រើយព្រែកម្ខាងផ្ទះទៅរកភូមិខ្មែរ យួនមួយក្បែរ ចិរ្រមទេត្ត ហៅថាភូមិ ១យ៉ូរ «ប្រែមកថាភូមិយួនស្រេង» ចម្ងាយពីភូមិចាក់ទ្រិងទៅប្រហែល ៣ គ.ម ។ ដើម្បីជៀសវាងគ្រោះថ្នាក់ដែលមានឡើង ក្នុងពេលឆ្លងកាត់ភូមិសត្រូវ យើងត្រូវពួនសំរាកដោយជ្រែកតាមព្រៃកំប៉ូត ។ ពេលដែលយើងចូលទៅដល់កន្លែងលាក់ខ្លួន ក្បែរមាត់ព្រែកសាកសពដែលអណ្តែតសន្សឹម ៗ តាមជំនោរទឹកក្បែរយើង បាននាំឲ្យយើងកើតក្តីសង្វេគនឹកគិតដល់បងប្អូនយើងឯព្រែកគយ នឹកដល់គ្រួសារយើង ដែលទើបទទួលការឈឺចាប់ព្រោះមានកូនប្រុសមួយស្លាប់ ដោយការនឿយហត់ និងតក់ស្លុត នៅពេលម្តាយនាំរត់កាត់វាលចម្ងាយ ៧ គ.ម និងនឹកដល់គ្រោះភ័យដែលរង់ចាំយើងថ្ងៃស្អែក ។ ពេលដែលយើងត្រូវឆ្លងកាត់ភូមិយួន តើយើងត្រូវអណ្តែតទឹក ដូចគ្នានេះដែរឬ ? ប៉ុន្តែក្តីកង្វល់ទាំងនេះ វានៅតែត្រឹមក្តីកង្វល់ វាគ្រាន់តែធ្វើឲ្យយើងដេកមិនលក់ ពីព្រោះវាសនាបងប្អូនយើងរាប់ម៉ឺននាក់បានដាស់ស្មារតីយើង មិនឲ្យមានក្តីរារែកអ្វីទៀតជាដាច់ខាត ។

នៅម៉ោង ៤ ទៀបភ្លឺ យើងរៀបចំចេញដំណើរ បំបែកគ្នាយើងជាក្រុមតូច ៗ ៣ ក្រុម ហើយយើងសន្យាទៅជួបគ្នានៅ ១យ៉ូរ ចាប់ពីម៉ោង ១០ ព្រឹកទៅទល់គ្នានឹងយប់ ។

ប្រហែលម៉ោង ៩ ស្រាងៗក្រោយពីចូលព្រែកក្រូចហើយក៏បំបែកគ្នាផ្សងព្រេងតែរៀងខ្លួន ៗ រហូតម៉ោង ៥ នៅកម្ពុជាក្រោមហៅ ក្រហមឯកើត «ព្រះអាទិត្យចាប់រះ» ស្នូរកាំភ្លើងបានឮឡើងប្រហែលជាមួយគីឡូម៉ែត្រពីយើងក្រោយបន្តិចមក ឮស្នូរផ្ទុះព្រុសព្រូចហ៊ឹងអឹងកងនៅកន្លែងដែលយើងឥតមានអ្វីទួលទៀតទេ បង ប្អូនរួមអាវុធក្រុមណាមួយត្រូវខ្មាំងប្រហារហើយ ៗ លុះយើងទៅដល់ ទយ៉ូវ ការស្មានរបស់យើងក៏ទៅជាការពិត ប្អូនខ្លួន និង ប្អូនពី ត្រូវឃ្មួនចាប់សម្លាប់ស្រេច ៗ

ពេលចូលទៅដល់ទីក្រុងនៅពេលយប់ មិត្តភក្តិយើងស្មោះ ១០ សាញ់ ដែលធ្លាប់បំរើការជាមួយគ្នាកាលជំនាន់នោះ បានជួយទាក់ទងជាមួយនាយទាហានជប៉ុនដែលរង់ចាំទំពសម្ពន្ធមិត្តមកជួញអាវុធ ហើយទិញអាវុធ ១២ ដើមតម្លៃតែពីរម៉ឺនព្យាស( Piastres )ញ៉ូយប៉ុណ្ណោះ ៗ

ចាប់តាំងពីយើងមានពីសក្តាម យើងរីករាយណាស់ ៗ រីករាយទៅទៀតត្រង់មិត្តភក្តិយើង គេជួយរើសអ្នកស្ម័គ្រចិត្តដែលគេទុកចិត្តទៅជួយយើងបាន ៨ នាក់ទៀត គ្រប់តាមចំនួនអាវុធ ១២ ដើម ៗ យើងសូមបើកដៃក្រចកបញ្ជាក់ថាអាវុធដែលទិញបាន យើងឥតហ៊ានបញ្ចេញឱ្យអ្នកផងឃើញទេ ពីព្រោះវាអាចទៅជានាំឱ្យគ្រោះថ្នាក់ដល់យើងផង

ដល់នាយទាហានជប៉ុនដែលអាណិតយើងនោះផង ។ នៅតាមផ្លូវវិលទៅព្រែក ឆយ ទៀតសោត យើងចេញដំណើរនៅពេលក្មេងដេកលក់ យើងស្រូតដំណើរតែមួយយប់ដល់ភូមិ ដៃនង ចម្ងាយប្រហែល ២០ គ.ម ពីឃ្លាំងដោយដើរកាត់តាមវាលស្រែឆ្ងាយពីភូមិអ្នកស្រុក ។

ពេលចូលដល់ភូមិ ដៃនង ដែលជាភូមិខ្មែរមួយស្ងាត់ស្ងៀម និងក្រោយពីបានលាក់អាវុធក្នុងព្រៃចាកមក យើងបង្ហាញខ្លួនឱ្យអ្នកស្រុកឃើញ ដើម្បីសាកសួរពីស្ថានការណ៍ទាំងមាត់សមុទ្រ ។ យើងស្នាក់នៅក្នុងភូមិនេះចំនួនមួយសប្តាហ៍ ឥតឱ្យមានលេចឮពីរឿងយើងមានអាវុធទេ ។ បានជាយើងត្រូវប្រើកលល្បិចដូចនេះ គឺព្រោះយើងចង់ឱ្យសត្រូវដែលតែងតែមកក្តោបផុតផ្ទះ កាប់សម្លាប់ បង ប្អូនយើងនោះ ចូលសិងយើងម្តងវិញ ។

នៅថ្ងៃ ១៨ មករា ១៩៤៦ អ្នកនាំសារមកពីសេនាធិការរបស់យើង បានមកឱ្យយើងដឹងថា មេទ័ពសួននៅកោះកុងដើម បានឱ្យយើងដឹងថា យើងត្រូវឈប់ឈ្លោះគ្នាហើយដើម្បីបង្ហាញការស្មោះត្រង់របស់យើង យើងត្រូវប្រគល់ទង់ជាតិរូបប្រាសាទទៅឱ្យគេ បើពុំនោះទេ គេនឹងទៅហៅទ័ពបន្ថែមពីខេត្តព្រះត្រពាំង មកកំទេចយើងឱ្យអស់ ។

ចំពោះការគំរាមកំហែងបោកប្រាសយ៉ាងនេះ យើងក៏

បានតបទៅគេវិញថា ទង់ជាតិរបស់យើងជ្រះបាត់នៅពេលប្រយុទ្ធគ្នា នៅបឹងព្រលិតនោះទៅហើយ ។ អង្វរគេឲ្យគេអាណិត ។

ដោយជួបប្រទះនិងស្ថានការណ៍ថ្មីបែបនេះ យើងត្រូវមានការប្រុងប្រយ័ត្នលើសដើម ដោយហេតុនេះបានជាយើងចាកចេញពីផែនដីដោយទូក ធ្វើដំណើរទៅតំបន់មាត់សមុទ្រដែលជាកន្លែងយួនធ្លាប់ចូលមកធ្វើបាបយើង ។

នៅតាមផ្លូវ លុះចូលទៅដល់ផ្ទះលោកតា ថាច់ ហ៊ុម នៅក្បែរសេនាធិការដ្ឋានយើង ក៏ស្រាប់តែមានអ្នកនាំសារបំបាយសេះមកឲ្យដំណឹងយើងថា អ្នកយាមនៅតាមមាត់សមុទ្រកូនក្អែក ឃើញពលនាវាទូកក្តោងជាច្រើននៅពេលព្រលប់ នៅចុងកោះពាក់កន្ទុល ត្រើយផ្ទៃសមុទ្រម្ខាងនៃជ្រោយកូនក្អែក«ជាកោះដែលល្បប់ទន្ទេមេគន្ថបក្ខបង្កើតឡើង» ។ ប្រហែលពីរម៉ោងក្រោយមក គឺវេលាម៉ោង ៦ ព្រឹក អ្នកនាំសារម្នាក់ទៀត បានមកដល់ប្រាប់យើងថា ទ័ពយួនចំនួន ២៧ ទូកសមុទ្រ បានចូលមកតាមទ្វារទំនប់ព្រែក កូនក្អែក ហើយចាប់បាញ់អ្នកស្រុក និង ដុតបំផ្លាញផ្ទះជាច្រើនខ្នង ។ អ្នកនាំសារបានបញ្ជាក់ទៀតថា បង ប្អូនយើងដែលរត់មកពីភូមិទ្វិនតាជីមកជួយ ចូលមិនចុះ ដោយយួនបាញ់ខ្លាំងពេកប៉ុន្តែបង ប្អូនទាំងនោះមិនព្រមត្រឡប់ទៅវិញទេ រង់ចាំ

យើងលើកគ្នាទៅជួយ ។ បង ប្អូន យើងខាង ក្នុងក្រែក អ្នកនៃគ្រោះ ដែលបានជម្លៀស ស្រី-ចាស់-ក្មេង ទៅភូមិ ដើមពោធិ៍និងទៅភូមិ ព្រែកគយ ក៏បានប្រដាប់កាំបិត ពូថៅ ចាំយើងដែរ ត្រង់នេះសូមបញ្ជាក់ថា បងប្អូនយើងឥតមាន ដំណឹងថាយើងមានអាវុធ ១២ ដើមនេះនៅឡើយទេ ។

ក្រោយពីយើងយកអាវុធពីទូកមកបង្ហាញគាត់លោកតា ថាច់ ហ៊ុម អាយុជិត ៦០ ឆ្នាំទៅហើយ តែដោយអំណាច សេចក្តីក្រេកអររបស់គាត់ ។ ស្ម័គ្រចិត្តទៅច្បាំងជាមួយ យើង ។ សូមជំរាបថា លោក ថាច់ ហ៊ុម ជាអាចារ្យវត្ត ពោធិព្រឹក្សផង ជាគ្រូភ្លេងពិណពាទ្យផង ជាគ្រូប្រក់ព្រំទ័ព យើងផង និងជាទីប្រឹក្សារបស់សេនាធិការយើងផង ។

ដើម្បីធ្វើឲ្យខ្មាំងបណ្តោយឲ្យយើងចូលកិត យើងក៏ សម្រេចចិត្តរុំកាំភ្លើងនិងកន្ទេលខ្លះ ខ្លះទៀតចងផ្ដោបឫស្សី ធម្មតា ។ សូម្បីបង ប្អូនយើងក៏ប្រចាំដែរ ។ យើងទៅ ដល់ទីលានប្រយុទ្ធវេលាម៉ោង ៨ ព្រឹក ។ នៅតាមផ្លូវបង ប្អូនយើង ដែលរង់ចាំយើង រាប់ច្រើនរយនាក់បាន «ហៃ» យើងទៅ គេហៃដោយសារគេទុកចិត្តទៅលើកាំភ្លើងប្រ មាញ់ពីរដើមដែលគេធ្លាប់ឃើញគ្រប់សមរភូមិមកហើយ ។ បង ប្អូនយើងខ្លះដែលស្ពាយទ្រព្យរបស់ពេក ក៏ស៊ូនៅតែ គេចចុះគេចឡើង តាមផ្លូវដើមផ្លូវក្នុងភូមិ ដើម្បីបណ្ដោះសត្

គាហនៈនិងរបស់ដែលនៅសល់ខ្លះ ។ ពេលនោះយួនឥតរវល់នឹងយើងទេ គេគិតតែពីសាងវិនាសកម្ម ។

នៅប្រហែល ៣០០ ម ពីភូមិ យើងចាប់ស្រាយរមូរកន្ទេល ស្រាយបំពង់ឫស្សី អ្នកស្រុកដែលដើរពីក្រោយគ្រាន់តែឃើញកាំភ្លើង ១២ ដើមថ្មីស្រឡាងភ្លាម ស្រែកហ៊ោរសឹងរបើកមេឃ លុះដើរបានប្រហែល ១០០ ម ទៅមុខទៀត ក៏ចំពួកយួនរត់សំរុកមករកយើង ស្រែកបណ្ដើររត់ចូលបណ្ដើរ ជាមួយកាំភ្លើងពីរដើម ដែលយើងឃើញច្បាស់ កាំភ្លើងឯទៀត ប្រហែលជាជាប់នៅការពារពួកដុតផ្ទះ ។ គ្រាន់តែឮស្នូរវា យើងដឹងស្រេចថា ជាកាំភ្លើងប្រមាញ់ ។

លោកតា ហ៊ឹម ដែលគាត់ទើបតែស្គាល់កាំភ្លើងជាលើកដំបូង ហើយទើបរៀនបាញ់ពេលមុនចេញពីផ្ទះសោះនោះ បានធ្វើឱ្យលោះកៃទៅត្រូវមេឃអស់មួយគ្រាប់ ។ យួនឮផ្ទុះនេះរឹតតែស្រែកៈ ទៀង- ទៀង- ទៀងគីយ . « ចូល- ចូល- ចូលឱ្យកិត » ខ្លាំងឡើង ៗ ដោយស្រែកប្រាប់គ្នាថាៈ « ស៊ីងយ៉ា » « កាំភ្លើងធ្វើអាយុ » លុះឃើញមួយគ្រាប់ទៀតល្បើកភ្លឺស្រែ ចំពួកយួនយៀកមិញក៏ទប់ដំណើរភ្លាម ប៉ុន្តែមួយប៉ព្រិចភ្នែកក្រោយមក ក៏បោលចូលមករកចំពេលយើងទាំងគំរោល ។ ការប្រឡូកគ្នា ក៏បាន

ចាប់ផ្ដើមឡើង ប្រៀបបានដូចខ្ទះទាំង ៧ ៗ

ប្រហែលជាកន្លះម៉ោងក្រោយមក ទ័ពខ្មែរ ដែលពោរពេញទៅដោយកំហឹងស្រាប់ ក៏បានវាយសម្លាប់ទ័ពយួនឲ្យដោះដៃពីភលស្រែ ថយចូលទៅរកភូមិដែលវាទើបបានដុតបំផ្លាញនោះវិញ ៗ លុះប្រកាប់ប្រចាក់គ្នានៅជុំវិញអស្ដិកំយនោះប្រហែល ១០ នាទីមក ទ័ពយួនក៏ត្រូវបង្ខំចិត្តលោតចុះក្នុងព្រែកកូនក្អែក ក្នុងគោលបំណងឆ្លងទៅត្រើយម្ខាងទៀត ប៉ុន្តែក្នុងចំណោមមនុស្សប្រហែល ២០០ ពាយនាក់ដែលបានលោតចុះក្នុងព្រែកនោះ មានមួយភាគត្រូវធ្លាក់ក្នុងអន្ទាក់របស់បង ប្អូន យើងដែលមកពីទិសតាំង ៗ ម្យ៉ាងទៀតទូកសមុទ្រចំនួន ២៧ គ្រឿង ដែលយួនយៀកមិញធ្វើដំណើរឆ្លងសមុទ្រ មកដុតបំផ្លាញផ្ទះ និងកាប់សម្លាប់ បងប្អូនខ្មែរយើង ដែលចងលាក់ក្នុងព្រែកក្បែរសមុទ្រ ក៏ត្រូវបង ប្អូនយើង មួយក្រុមទៀតមកពីបឹងត្រលិត បំផ្លាញខ្ទេចខ្ទីអស់ដែរ ៗ យួនឯទៀត ដែលបាក់ទ័ពគេប្រសេចប្រសាចពីលានប្រយុទ្ធ បានរស់រានមានជីវិតខ្លះ ក៏ដោយសារតែរត់ទៅពួនក្នុងព្រៃចាក នៅក្បែរមាត់សមុទ្រ ឬនៅតាមភូមិយួនដែលស្ថិតនៅឆ្ងាយពីសមរភូមិ ៗ

ក្រោយពីបានទទួលជោគជ័យ និងប្រមូលបានអាវុធ ១០ ដើមផង និង ព្រួញ- ស្នា- លំពែង- កាំបិតយួនគិច

ប្រហែលចំណុះ មួយទូកមក និងក្រោយពីបានប្រគល់អ្នករបួសឱ្យក្រុមចិននៅក្នុងក្អែកជួយព្យាបាលនិងសំដែងសមានទុក្ខចំពោះគ្រួសារអ្នកស្លាប់ ២០ បាយនាក់នោះមកយើងក៏បាននាំឱ្យក្រុមកាកបាទក្រហម ដែលកើតឡើងក្នុងជំនាន់យៀកមិញ ជួយប្រមូលសាកសពយួន យកទៅកប់ឱ្យបានត្រឹមត្រូវផង ។

មិនតែប៉ុណ្ណោះ យើងបានចែកគ្នាឱ្យចេញទៅល្បាតតាមមាត់សមុទ្រចំនួនច្រើនថ្ងៃ និងបានចាត់គ្នាយើងពីរក្រុមទៀត ឱ្យដើរល្បាតគ្រប់ទិសទី ដើម្បីទប់ទល់នឹងប្រតិកម្មផ្សេង ៗ ដែលអាចកើតមានឡើងពីខ្មាំងទៀត ។

*    *

*

បន្ទាប់ពីការទប់ទល់ប្រកបដោយជោគជ័យនេះចំនួនប្រហែល ១៥ ថ្ងៃមក ក៏គ្មានឃើញហេតុភេទអ្វីជាដុំកំភួនកើតឡើងទៀតទេ រីឯការកាប់សម្លាប់គ្នានៅតាមភូមិនានា ក៏មានការថមថយច្រើន ។

ប៉ុន្តែវិនាសកម្ម បានផ្ទងទៅបង្ករបង្កើតនៅក្នុងខេត្តតលលាវឯណោះ ហេតុដូចនេះហើយ បានជាយើងត្រូវរំលែក

គ្នាទៅជួយ បង ប្អូនភូមិស្វាយ ហើយជំរុលទៅចាប់ដៃខ្លឹង លោកគ្រូ គិន ហៅហៅហ្វាយ គិន ដែលជាអ្នកដឹកនាំចលនាតស៊ូរបស់បង ប្អូនយើងនៅស្រុកជ៉ាយញា ខេត្តគលសារ ។ ពេលត្រឡប់វិលវិញ យើងបានវាយរំដោះ បានអ្នកជាប់ឃុំចំនួន ៣៧ នាក់ ដែលសត្រូវទុកយកទៅឱ្យ « រាវបន្តង » នៅពេលចូលឆ្នាំចិន-យួន ។ រាវបន្តង ជាកាសិតយួនពុត្តិលការសម្លាប់មនុស្សដោយច្រមុជទឹក ឬ កាប់បណ្ដែតទឹក ។

# ពន្លឺសន្តិភាព

ក្រោយការប្រយុទ្ធនៅ ភូនភ្លុក និងក្រោយពីយើងត្រឡប់មកពីជួយបង ប្អូនយើងនៅខេត្តពលលាវចំនួនប្រហែលមួយខែមក ទ័ពសម្ព័ន្ធមិត្ត មិនទាន់ហ៊ានចូលមកធ្វើការរៀបរយវិញទេ ប៉ុន្តែជាមួយគ្នានេះ ការស្ងប់ស្ងាត់ក៏កើតមានឡើងសឹងគ្រប់ទិសទី ក្នុងតំបន់មួយ ដែលមានផ្ទៃដីទំហំប្រហែល២០០ គ.ម.២. សាកសព ដែលធ្លាប់ឃើញអណ្ដែតតាមព្រែកនានា រាប់រយរាប់ពាន់ ខ្លះរលេះ រលួយអស់ទៅហើយ ខ្លះក៏អណ្ដែតកាត់ទីប្រជុំជន បាយនៅ ចេញទៅសមុទ្រអស់ទៅដែរៗ

រក់ងយប់ថ្ងៃទី ៦ កុម្ភៈ ១៩៤៦ គេឃើញលោកតាចៅអធិការ ជាំ ពេជ លោកតាអាចារ្យ ជាំ ហ៊ឹម លោកតាសារ ជាអ្នកបំរើព្រះសង្ឃក្នុងវត្តពោធិព្រឹក្ស មេចិនឈ្មោះ ហួរ ហៅថៅកែ ហួរ អតីតមន្ត្រីយួនឈ្មោះ វិញ យ៉ុវិង ហ ហៅ ធា ហ អុងកាឡា និង គ្រីង យ៉ាង យ៉ំ ម្ចាស់ហាងលក់មាស «មានគ្រួសារជាខ្មែរ» ចាងហ្វាងសា

លាចិនដែលយើងកួចឈ្មោះ ហ៊ា មេង ហ៊ា ប៊ុ ហ៊ា គួយ ជាអ្នកមានធនធានស្តុកស្តម្ភ បានខិតខំ និងអញ្ជើញមកជួបយើងក្នុងសេនាធិការដ្ឋាន ក្នុងឋានះជាអ្នកនាំពាក្យរបស់ពលរដ្ឋយួន និងចិន នៅផ្សារព្រែកតយ ដោយស្នើសុំយើងជួចគេទេ :

—សូមឱ្យលើកសេនាធិការដ្ឋានទៅឯទីប្រជុំជន ដោយគេជូនផ្ទះមួយល្វែង ។

—សូមជួយណែនាំខ្មែរ និងយួន ឲ្យនិយាយស្តាប់គ្នាបាន លែងប្រកាប់ប្រចាក់គ្នាតទៅទៀត ។

ចំពោះការស្នើរបស់អ្នកនាំពាក្យនេះ យើងបានជំរាបបញ្ជាក់ថា: ដែលយើងទៅទ្រលំបាកាថាលស្រែ ខោលស្រវាសពេញវាលផូចនេះ ក៏ដើម្បីសេចក្តីសុខ និងយុត្តិធម៌ ប្រសិនគេមានបំណងជួចយើងដែរ យើងគ្មានការអ្វីនឹងបញ្ជាក់ទៀតទេ ។

មួយថ្ងៃក្រោយមកទៀត ក្រោយពីបានចាត់ការឱ្យប្រុងប្រយ័ត្នគ្រប់ច្រកល្ហកទ្វារឡើងទៀត យើងក៏បានទៅថ្វាយបង្គំលោកតា តេជ ដើម្បីស្នើយោបល់ក្នុងរឿងនេះ ពីព្រោះយើងពិបាកនឹងទុកចិត្តគេដែរ តាមឧបត្ថិហេតុ ដែលយើងបានឃើញជាហូរហែរហូតមកថ្ងៃនេះ ។ ចំពោះយើងវិញ យើងឥតមានសង្ស័យបន្តិចបន្តួចសោះទេថា: លោក

ប្រយុទ្ធនៅ កូនក្អែក ដែលទើបកន្លងទៅនេះ បានធ្វើឱ្យយួនមានការត្រិះរិះមិនតិចឡើយ ជាពិសេស គេទើបដឹងហើយឃើញថា យើងប្រាកដជាមិនព្រមស្លាប់មែន ។

ដោយត្រូវគោរពនូវពាក្យបុរាណដែលតែងថា បើដេញទាន់ កុំដាច់កែងនោះ យើងក៏បានធ្វើបទបញ្ជាឱ្យយួនចាប់គ្នាគេទៅហៅមនុស្ស «រាប់ទាំងពួកកងទ័ព ឬ យួកិច» ផង រាប់ច្រើនម៉ឺននាក់ ទៅនៅតាមកោះនានា នៅតាមសមុទ្រ ជាពិសេសនៅ កុងដីម ដែលចូលមកធ្វើបាបយើងច្រើនលើក ច្រើនគ្រានោះ មកសុំចុះចូលនឹងយើងសិន ។

គ្រាន់តែបានដំណឹងនេះភ្លាម ពីរថ្ងៃក្រោយមកមនុស្សម្នាទាំងពាន់ ៗ បានចូលសុំសំបុត្រចុះចូល ៗ ពេលនោះ យើងដែលគ្មានប្រាក់បំណាច់អ្វីមួយសេនគាំទ្រពីដើមទីមក ក៏សុំឱ្យម្នាក់ ៗ ដែលសុំចុះចូល បង់មួយពីយ៉ាស ពីព្រោះយើងត្រូវប្រើស្បៀងជិត២០នាក់ ទើបសារសៅទាន់ ។

ដោយឃើញថា ក្នុងកំឡុងតែកន្លះខែសោះ មនុស្សម្នាបានចូលមកប្រកបមុខរបរដូចធម្មតាសឹងគ្រប់កន្លែង ដូចនេះ យើងក៏ចាប់មានការទុកចិត្តលើសុទ្ធចិត្តរបស់យួនបន្តិចម្តង ៗ ទៅដែរ ។

* * *

# ពិធីបុណ្យ
# ប្រោសស្រង់សព្វសត្វ

ដើម្បីរំលឹកដល់វិញ្ញាណក្ខន្ធនៃពុទ្ធជនយើង ដែលបានបូជាជីវិតដើម្បីសេរីភាព និងយុត្តិធម៌ និងបងប្អូនយើងផ្សេងទៀតដែលបាត់បង់ជីវិតក្នុងរាល់អន្តរកាលនេះ យើងក៏បានធ្វើបុណ្យបីថ្ងៃ បីយប់ ក្នុងបរិវេណវត្តពោធិព្រឹក្ស ហៅវត្តចាស់ ។ នៅពេលនោះមានប្រតិភូ យួន-ចិន ស្ទៀក គាត់ជាពុទ្ធមាមកជន តាមរបៀបជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងមហាយានប្រហែលជា ៣០ ក្រុយនាក់ ដឹកនាំដោយមេចិន និងមេយួននៅទីនោះ ដូចជាលោក ធៀង យ៉ាងចាយ ហៅចីការ ចាយ និងអស់លោកអតីតអ្នកម៉ុង អ្នកតារ ចិន- យួន ជាច្រើន បានមកចូលរួមក្នុងពិធីបុណ្យយើងនេះផង ។

នៅថ្ងៃទី ៣ មុនពេលធ្វើបុណ្យ លោកតា ចាប់ ហ៊ឹម ដែលទើបវិលមកកាន់នាទីចាស់របស់គាត់ក្នុងវត្តវិញ ក្រោយពីបានចូលរួមក្នុងការប្រយុទ្ធមួយដ៏ឃោរឃៅនៅ ភូនក្អែក នៅពេលថ្មីៗនេះមក បានឡើងធ្វើសុន្ទរកថាមួយទៅកាន់បង ប្អូនយួនបញ្ជាក់ពីឆន្ទៈប្តូរផ្តាច់របស់យើង ចំពោះអំពើអយុត្តិធម៌ និងពីគោលបំណងរបស់យើងទៅអនាគត ។ ដើម្បីតបសន្តជាលោកតា ចាប់ ហ៊ឹម អតីតចៅសង្កាត់យួន ហៅ ដា ហស់ បានធ្វើការផ្តែផ្តាំដល់គណរដ្ឋយួន ឲ្យខិតខំស្រោចស្រង់មិត្តភាពជាមួយ បងប្អូនយើងវិញ ពីព្រោះយួន និង ខ្មែរ ត្រូវរួមរស់ជាមួយគ្នាតទៅទៀតនៅលើដីនេះ ទោះយើងទាំងអស់គ្នា ចង់ក្តី មិនចង់ក្តី ។

# សកម្មភាព និង រឿង អាពីលស្រុកយើង

## ១-សកម្មភាពចៅហ្វាយស្រុកថ្មី

រវាងខែមីនា ១៩៨៦ លោកអភិបាលខេត្តឃុនចួលមក ដល់ព្រែកតយជាមួយទាំសម្ព័ន្ធមិត្តជាលើកដំបូង គាំងពី ជំបុំខបាញ់សង្គ្រាមទៅ គេបានលើក«បន្ទុប» ថៅដោយ ដាក់ ឱ្យធ្វើជាអភិបាលស្រុកអណ្ដូងទឹក ដែលមានការិយាល័យថ្មី នៅផ្សារព្រែកតយតែម្ដង ។ នៅក្នុងសន្តិការបស់គេ ដែល យើងអាចសន្និដ្ឋានបានថា ពិតមែនតែគេមិនបានយល់ ស្របនឹងសកម្មភាពរបស់យើងពីបុន្មានខែមុននេះក៏ដោយ ក៏ គេមិនទុកថាយើងធ្វើនោះខុសទាំងអស់ដែរ ដោយនៅទីអវ-សាននៃសន្តិការបស់គេៗ បានបញ្ជាក់យ៉ាងច្បាស់ថា . . . ពិតជាដើម្បីជាតិ ដើម្បីប្រទេស ៗ

២— នៅក្នុងមុខដំណែងថ្មីនេះ ចៅហ្វាយស្រុកយើងបានតាំងមន្ត្រីសង្កាត់គ្រប់សង្កាត់ក្នុងស្រុក ដោយយើងបានចាត់តាំងភ្នាក់ងារសង្កាត់គ្រប់សង្កាត់ក្នុងស្រុក ដោយរើសបានតែមនុស្សដែលមានកំណើតជាខ្មែរ ៗ ពលរដ្ឋយួនត្រូវទទួលតែត្រឹមតំណែង មេភូមិ ឬ ស្មៀន ហើយសម្រាប់តែសង្កាត់ណាដែលមានសុទ្ធតែពលរដ្ឋយួនរស់នៅ ៗ

ដើម្បីបង្ហាញនូវសុទ្ធចិត្តរបស់យើង យើងបានខិតខំប្រឹងប្រមូលខ្មែរ និង យួនឲ្យរួមរស់ជាមួយគ្នាដូចដើម ដើម្បីបំពេញកិច្ចការរួម ដោយឥតមានប្រកាន់ជាតិសាសន៍សោះឡើយ ៗ ក្រោយមកទៀត រដ្ឋការយួនក៏បានប្រគល់អាវុធ និង គ្រាប់រំសេវជាច្រើនមកដល់យើង ដែលយើង និង យួនបានប្រើអាវុធនោះជាមួយគ្នា ដើម្បីបង្ក្រាបអំពើចោរកម្ម ដែលមានកើតឡើង ដោយសារអ្នកទោសរត់ពីកោះត្រឡាចបង្ករបង្កើតឡើង ៗ

៣ មានការរំដោះលោកសង្ឃ និងដូនជីកាតូលិកនៅភូមិជង់ក្ដាន់ ឲ្យចាកផុតពីក្ដីអន្តរាយ ៗ បានកំចាត់ក្រុមចោរកំណាចមួយក្រុម នៅពេលដែលវាកំពុងចាប់កូនក្រមុំអ្នកស្រុក និងជញ្ជូនឥវ៉ាន់ដាក់ក្នុងទូកប្រុងទុកទៅពួនតាមកោះក្នុងសមុទ្រ ៗ ក្រោយពីចោរកាប់ចំដោយ ជាតិ បាក់កាំភ្លើងនៅពេលប្រតាយប្រតប់គ្នាមក អ្នកស្រុកមួយក្រុមបានចូលជួយ

ប្រយុទ្ធ ហើយចាប់បានមេកំយកទៅសម្លាប់ភ្លាមទៅ ។ អ្នកដែលសម្លាប់អាចោរ មានផុកខាងកញ្ញានង្គ្រោះ អ្នកម្ចាស់របស់ និងក្រុមញាតិជាមួយអ្នកភូមិផងរបងជាមួយ នៅក្នុងភូមិមួយនៅជិតភូមិមាន់គោង ។

៤— រួចហើយយើងក៏ចាត់ចែងចែកអំបិល រាប់ច្រើន ពាន់តោនសល់ពីជំរុំ ហើយដែលជាប្រភពមួយដែរក្នុងជម្លោះរវាងយើង និង យួន ម្ដងនោះដោយគ្មានប្រកាន់ពូជសាសន៍ដូចមុនៗទៀតឡើយ ។

៥- តាមការអំពាវនាវរបស់យើង ពលរដ្ឋយួន-ចិន នៅផ្សារព្រែកតយ-ភូនក្អែក-បឹងព្រលឹត បានរួបរួមគ្នា ជាមួយយើងដើម្បីជួសជុលវត្តភូនក្អែកឡើងវិញ មិនតែប៉ុណ្ណោះ យើងបានកសាងស្ពានឈើបានពីរនិងរៀបចំផ្លូវក្បែរវត្តពោធិព្រឹក្ស ដោយយួន-ចិន គេសុខចិត្តចំណាយខ្មោចជីដូន-ជីតាគេចេញ ដើម្បីបង្ហាញការស្មោះត្រង់ របស់គេមកលើប្រយោជន៍រួមផង បង្ហាញថាយើងនិងយួនល្មមជឿគ្នាវិញបានផង ។

# យោបល់រួម

ក្រោយពីបានអានអត្ថបទនេះមក អស់លោកអ្នកអាចផ្ទុះឃើញថាខ្មែរនិងយួននៅកម្ពុជា ក្រោយដែលស្ថានភាពភូមិសាស្ត្រ បានតម្រូវឲ្យរស់ជាមួយគ្នាអស់កល្បអស់កាលនោះ មានប្រយោជន៍អ្វីនឹងយកគ្នាជាសត្រូវ ? ក្នុងករណីយនេះ ប្រសិនបើអ្នកអ្នកការនៅទីនោះ នោះមានបាន:ទាយក្តុចយ៉ាងណាក្តី ក្រោយនេះ ត្រូវឃើញ នូវហេតុភេទទាំងឡាយដែលយួន បានបង្ករមកលើពលរដ្ឋខ្មែរតាំងពីដើមទីតិតាំងពីមានភាពនៅជាផ្សងនោះឡើយ ឡើះការកាប់សម្លាប់គ្នា ព្រោកដ៏ជាកុំមានកើតឡើងបានទេ។ ម្យ៉ាងទៀត ព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងបានបញ្ជាក់ទៀតថា ជាតិសាសន៍ណាដែលមិនខ្លាចស្លាប់ ព្រោកផងរស់ នេះហើយ ជាសេចក្តីសន្និដ្ឋានរបស់យើង ។

ជាទីអវសាននៃអត្ថបទនេះ សូមបញ្ជាក់ថា យើងឃើញការរួមរស់រវាងយើង និងយួន ជាមិត្ត យើងនៅកម្ពុជាក្រោយពីអតីតកាល និងនៅបច្ចុប្បន្នកាល មានភាពយ៉ាងណាៗ នោះហើយ រីឯអនាគតកាលវិញ មានតែពេលវេលា និងប្រវត្តិសាស្ត្រទេដែលអាចបង្ហាញឲ្យយើងឃើញបាន ។ ប៉ុន្តែអ្វីដែលយើងដឹងប្រាកដ គឺស្ថានភាពភូមិសាស្ត្របានតម្រូវ និងតម្រូវទៅទៀតឲ្យយើង និងយួន ជាមិត្តយើងរស់នៅជាអ្នកភូមិជិតខាងជាមួយរហូតរៀងអស់កល្ប ទោះយើងចង់ក្តី មិនចង់ក្តី ។

ដូចនេះ ព្រឹត្តិការណ៍ដែលបានកន្លងទៅហើយចាប់ពីឆ្នាំ ១៩៤៥ នោះត្រូវយើង និងយួន ព្រមសុខចិត្តចាត់ទុកថាជានិមិត្តដ៏អាក្រក់ទៅចុះ ហើយបន្តការរួមរស់របស់យើងតទៅទៀត ។ ដើម្បីទៅដល់គោលការណ៍នោះខ្មែរ និងយួន ត្រូវជៀសវាងអ្វីដែលអ្នកខ្លះអាចចាត់ទុកថាជាការរំលោភ អមិត្ត អមនុស្សធម៌ ។ល។ ពោលគឺអ្វីដែលមិនមែនជាសញ្ញាសន្តិភាព ជាពន្លឺយុត្តិធម៌ ហើយរួមគ្នាកសាងសម្របសម្រួលក្នុងគំនិតកសាងតទៅ ។

* * *

# តារាងរាយឈ្មោះជាខ្មែរ នៃខេត្ត-ស្រុក-សង្កាត់
## ពិសេសពីព្រះនៅកម្ពុជាក្រោម ដែលបានបោះពុម្ពក្នុងរឿង...
## «រស់ ព្រោះយ៉ាងណាឡាប់» ហើយប្ដូរឈ្មោះជាយួនដល់សព្វថ្ងៃ

| ឈ្មោះដើមជាខ្មែរ | ឈ្មោះជាយួន លើកទី ១ | ឈ្មោះជាយួន ពេលឥឡូវនេះ | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ខេត្តឃ្លាំង «បាសាក់» | Soctrang | Baxuyên | ខេត្តឃ្លាំង |
| — ក្រមួនសរ | Rachgia | Kiên Giang | |
| — ព្រះត្រពាំង | Travinh | Vinh Binh | |
| — ព្រែកឫស្សី | Cantho | Phong Dinh | |
| — ពាម បារាជ | Long Xuyen | An Giang | |
| — មាត់ ជ្រូក | Chaudoc | Chaudoc | |
| — ពល លាវ | Baclieû | Baclièn | |
| — ទួលតាមោក | Thudaumot | Binh Duong | |
| — ទឹកខ្មៅ | Camau | An Xuyen | |
| — ឫ កាប់ | Cap St Jacques | Vung Tau | |
| ស្រុក អណ្ដូងទឹក | Long Phu | Long Phu | |
| សង្កាត់ ព្រែកគយ | Rachgoi | Rachgoi | |
| — ព្រែកចាក | Chac Vàng | Chac Vàng | |
| — ផ្ដៅពេជ | Lo Viéng | Lo Viéng | |
| — ផ្ដៅកំបុត | ឥតប្រែ | ឥតកែប្រែ | |

| | | | |
|---|---|---|---|
| សង្កាត់ជង់ក្ដាង | Bai Gia | Bai Gia | |
| — គូទក្អែក | Ngang Hô | Ngang Hô | |
| — ដើមពោធិ | Lam Vô | Lam Vô | |
| — ទ្វីន តាដើ | Dinh My | Dinh My | |
| — កំពង់ ពេលីទាល | មិនចាំ | មិនចាំ | |
| — ផៃ ថនិ | Lièu Tü | Lièu Tü | |
| — បឹង ត្រលឹត | Bùng Lúc | Bùng Lúc | |
| — តាខោរ | Bàng Làng | Bàng Làng | |
| — បឹងទ្រៀក | មិនចាំ | គ្មាន | |
| — បឹងអន្សោរ | Bùng Sa | គ្មាន | |
| ភូមិ មាន់គោង | មិនចាំ | មិនចាំ | |
| — ទន្លេ ឯគៀង | My Thanh | My Thanh | |
| — ឯលិច | Lich Hoi Thuong | Lich Hoi Thuong | |
| — ឯកើត | មិនចាំ | មិនចាំ | |
| — ប្រហាត | មិនចាំ | មិនចាំ | ខេត្ត ពលលាវ |
| — យ៉ា រ៉ាយ | ឥតមានប្រែ | ឥតមានកែប្រែ | |
| — ផ្សារវក្កាត | Giâng Nôi | Giâng Nôi | |
| — ដរាំ តិច | គ្មានឈ្មោះជាខ្មែរទេ | ជាភូមិកើតថ្មី | |
| — ដរាំ យើយ | —ដ— | | |
| — ព្រែក ហ្វាទុង | ព្រែកហ្វាទុង | ព្រែកហ្វាទុង | |

# 'គួរឲ្យប្រែរមោចក្នុងចិត្តណាស់ កាលយើងឃើញភូមិមានឈ្មោះជាខ្មែរ ហើយបែរពុំមែនជារបស់ខ្មែរនៅវិញ...'



គ្រួសារខ្មែរមួយគ្រួនៅខេត្តឃ្លាំង (កន្លែងកើតហេតុ)
'ក្លាយទៅជាឈ្នួលបម្រើយួនៗ...'

[illegible] បណ្ណាគារ នគរធំ
ផ្ទះ ៥៦-៥៨ [illegible]

តម្លៃ ៤០ រៀល

ម៉ៃ ខាត

# ...រស់ព្រោះហ៊ានស្លាប់



ឆាកប្រយុទ្ធ ខ្មែរ-យួន នៅកម្ពុជាក្រោមក្នុងឆ្នាំ ១៩៤៥-៤៦

ឯកសារដែលគេកម្រជួបប្រទះ